01335390



**នៅចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

**ភាគីដាក់ឯកសារ:** សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

**ដាក់ជូន:** អង្គជំនុំជម្រះតុលាការកំពូល

**ភាសាដើម:** អង់គ្លេស និងខ្មែរ

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៦

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 28-Sept-2016, 15:28
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ:** សាធារណៈ/Public

**ឋានៈនៃចំណាត់ថ្នាក់ឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

---

# បណ្តឹងសាទុក្ខឆ្លាមៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះសំណើសុំការបញ្ជាក់ពីវិសាលភាពទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

:

**នៅចំពោះមុខ៖**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម A. KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម C.N. JAYASINGHE

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele Mwachande MUMBA

សំ សុគង់

វ៉ែន ពៅ

ទី ស្រ៊ីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ

**មេធាវីប្រចាំការ៖**

ទូច វរល័ក្ស

Calvin SAUNDERS

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

Olivier BAHOUGNE
Patrick BAUDOUIN
Beini Ye

## I. សេចក្ដីផ្ដើម

1. សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី (សហមេធាវីនាំមុខ) សូមដាក់បណ្ដឹងសាទុក្ខភ្លាមៗនេះ ("បណ្ដឹងសាទុក្ខភ្លាមៗ") ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ដែលមានចំណងជើងថា "សេចក្ដីសម្រេចលើសារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន៩២ នៃវិធានផ្ទៃក្នុង ស្ដីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទិននឹងការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈនៅក្រោមបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ("សេចក្ដីសម្រេចដែលរងការជំទាស់")។

2. សហមេធាវីនាំមុខយល់ឃើញថាថា សេចក្ដីសម្រេចដែលរងការជំទាស់ គឺជាការបញ្ចប់នៃដំណើរការនីតិវិធីប្រឆាំងនឹងសហជនជាប់ចោទ។ សហមេធាវីនាំមុខសន្និដ្ឋានថា ការចេញសេចក្ដីសម្រេចដែលរងការជំទាស់ នឹងបង្កើតឲ្យមានជា កំហុសលើអង្គច្បាប់ ដែលនាំអោយមោឃៈសេចក្ដីសម្រេចនោះ។ សហមេធាវីនាំមុខយល់ឃើញផងដែរថា សេចក្ដីសម្រេចដែលរងការជំទាស់នេះ កើតចេញពីការភ័ន្តច្រឡំដែលគេអាចដឹងបានជាមុន ពាក់ព័ន្ធនឹងការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ហើយដែលការភ័ន្តច្រឡំនេះនាំអោយប៉ះពាល់ដល់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

## II. ប្រវត្តិនីតិវិធី

### (ក) ដំណាក់កាលបុរេជំនុំជម្រះ ៖ ការចោទប្រកាន់ និងដីកាដំណោះស្រាយ

3. កាលពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ នួន ជា ត្រូវបានចោទប្រកាន់ជាលើកដំបូងពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមានមនុស្សឃាត ការធ្វើទារុណកម្ម ការដាក់ជាទាសករ ការដាក់ឃុំឃាំង ការធ្វើទុកបុកម្នេញ ការសំលាប់ផុតពូជ ការនិរទេស ការជន្លៀសដោយបង្ខំ និងអំពើអមនុស្សធម៌ដទៃទៀត "ដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ៥ [...] នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ"[1]។ កាលពីថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ខៀវ សំផន ត្រូវដាក់ឲ្យនៅ

---

[1] កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល ឯកសារ E3/558 ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រ ២។ វិធាន ៥៧(១) នៃវិធានផ្ទៃក្នុង បញ្ជាក់អំពីការជូនដំណឹងអំពីបទចោទប្រកាន់ថា "នៅពេលជនត្រូវចោទចូលបង្ហាញខ្លួន ចំពោះមុខសហចៅក្រមស៊ើប

*បណ្ដឹងសាទុក្ខភ្លាមៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះសំណើសុំការបញ្ជាក់ពីវិសាលភាពទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈនៅក្រោមបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

ក្រោមការពិនិត្យពីបទល្មើសប្រឆាំងនឹងមនុស្សជាតិ "ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ [...] នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ"[2]។

4. កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាដោយបានកត់សម្គាល់អំពី "ភាពមិនជាក់លាក់" ដែលបង្កើតឡើងដោយការពិព័រណ៌នាអំពីបទល្មើសដែលត្រូវបានចោទប្រកាន់នៅពេលដែលជនត្រូវចោទបានចូលមកបង្ហាញខ្លួនជាលើកដំបូង បានស្នើឲ្យ សហចៅក្រមស៊ើបអង្កេតធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់នូវបទចោទទាំងឡាយប្រឆាំងនឹងជនត្រូវចោទ ក៏ដូចជាត្រូវជូនដំណឹងថា៖

> "កិច្ចស៊ើបសួរនៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដែលកំពុងធ្វើជាបន្តបន្ទាប់ទៅនេះ គឺពន្លាតទៅដល់គ្រប់រឿងរ៉ាវទាំងអស់ដែលបានចោទប្រកាន់លើពួកគាត់ និងពន្លាតទៅដល់គ្រប់បទចោទទាំងអស់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលសហព្រះរាជអាជ្ញា បានធ្វើឡើងប្រឆាំងនឹងពួកគាត់ និង ខ) បទល្មើសនានាដែលពួកគាត់អាចនឹងត្រូវបានបញ្ជូនខ្លួនទៅជំនុំជម្រះនៅពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចស៊ើបសួរ គឺមិនកំណត់ត្រឹមតែបទល្មើសជាក់លាក់នានា ដែលពួកគាត់ត្រូវបានធ្វើការចោទប្រកាន់នៅពេលចូលបង្ហាញខ្លួនលើកដំបូងប៉ុណ្ណោះទេ ក៏ប៉ុន្តែផ្ទុយទៅវិញ គឺមានថែមទាំងរាល់ឧក្រិដ្ឋកម្មទាំងអស់ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទៀតផង (ដោយរាប់បញ្ចូលទាំងអំពើប្រល័យពូជសាសន៍ និងការរំលោភលើក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ផង) ដែលអំពើឧក្រិដ្ឋកម្មដែលកំពុងធ្វើការស៊ើបសួរទាំងនោះ អាចនឹងត្រូវបានកំណត់ជាបទចោទទៅតាមច្បាប់។[3]"

5. កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ឡើងវិញអំពី "កាតព្វកិច្ចរបស់ខ្លួន" ដូចមានចែងនៅក្នុងវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង ក្នុងការស៊ើបអង្កេតផ្នែកអង្គហេតុទាំងអស់ (អង្គហេតុ) ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ (រួមទាំងនៅ

---

អង្កេតជាលើកដំបូង សហចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជននោះ និងប្រាប់ជននោះអំពីបទ ចោទប្រកាន់ និងអំពីសិទ្ធិមាន មេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ។"

[2] កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល ឯកសារ E3/557 ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រ ២។

[3] សំណើរបស់សហព្រះជាអាជ្ញា សុំឲ្យធ្វើការបំភ្លឺអំពីបទចោទ ឯកសារ D198 ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩, កថាខណ្ឌ ១៧។

ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម) ដែលបានបញ្ជូនមកខ្លួន[4]។ សហចៅក្រមស៊ើបអង្កេតសម្រេចថា៖

> "សហចៅក្រមស៊ើបអង្កេតនឹងវិនិច្ឆ័យលើអង្គហេតុទាំងមូលនេះ និងលើការកំណត់ប្រភេទបទល្មើសជាក់ស្តែងដែលស្នើឡើងដោយសហព្រះរាជអាជ្ញា (ដែលរួមមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបទល្មើសជាតិក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦) ក្នុងនោះសហចៅក្រមស៊ើបអង្កេតអាចនឹងបញ្ជូនជនត្រូវចោទទៅជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីការដាក់ពួកគេឲ្យឋិតនៅក្រោមការពិនិត្យ ឬចេញដីកាលើកលែងការចោទប្រកាន់ចំពោះអង្គហេតុទាំងមូល ឬដោយផ្នែក"។[5]

6. កាលពីថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ "បន្ទាប់ពីការពិនិត្យលើភស្តុតាងដែលទទួលបានពីសហករណ៍ និងការដ្ឋាននានា មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សនានា" ក.ស.ច.ស បានកំណត់ បទចោទនានាដែលត្រូវបានជូនដំណឹងទៅ នួន ជា នាពេលបង្ហាញខ្លួនជាលើកដំបូង និងសម្រេចថា "នួន ជា ត្រូវស្ថិតក្រោមបទចោទផ្សេងៗទៀត" ហើយអាស្រ័យហេតុនេះ បានចោទគាត់បន្ថែម *ដែលក្នុងចំណោមបទចោទនោះ* មាន "ការរំលោភសេពសន្ថវៈ" ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចបានកំណត់នៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[6]។ ស្រដៀងគ្នានេះដែរ កាលពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេត បានកំណត់ពីបទចោទនានាដែលត្រូវបានជូនដំណឹងដល់ ខៀវ សំផន នាពេលបង្ហាញខ្លួនជាលើកដំបូង ក្នុងនោះមានទាំង "ការរំលោភសេពសន្ថវៈ" ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផងដែរ[7]។

7. កាលពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត បានចេញដីកាដោះស្រាយដែលមានទាំងការចោទប្រកាន់ផ្នែកអង្គហេតុចំពោះព្រឹត្តិការណ៍នានា នៃការរំលោភសេពសន្ថវៈ នៅមន្ទីរសន្តិសុខ និងនៅតាមសហករណ៍នានា[8]។

---

[4] ដីកាសម្រេចលើ សំណើរបស់សហព្រះរាជអាជ្ញា ឯកសារ **D198/1** ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៦។

[5] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៦ (សេចក្តីបញ្ជាក់បន្ថែម)។

[6] កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ, **D275**, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩, កថាខណ្ឌ ១១។

[7] កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ, **D3/576**, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩, កថាខណ្ឌ ១០។

[8] ដីកាដំណោះស្រាយ, **D437**, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ"), កថាខណ្ឌ១៤២៦-១៤២៨។

៤៥៧. នៅក្នុងសាលក្រមនៃសំណុំរឿង ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ អង្គជំនុំជម្រះសាលា ដំបូងបានសន្និដ្ឋានថា មានករណីរំលោភផ្លូវភេទមួយដែលបានប្រព្រឹត្តនៅមន្ទីរ ស-២១។ បុគ្គលិក មន្ទីរ ស-២១ ម្នាក់ បានយកឈើរុកចូលទៅក្នុងប្រដាប់ភេទរបស់អ្នកទោស ស្រីម្នាក់ នៅក្នុងអំឡុងពេលសួរចម្លើយ។ បើតាមសម្តីរបស់ ឌុច ក្រោយពេលករណីនេះត្រូវ បានរាយការណ៍ឲ្យឌុច ឌុចបាន ពិគ្រោះយោបល់ពីរឿងនេះជាមួយ ហ៊ី។ គាត់បានអះអាងថា គាត់បានឲ្យ ហ៊ី ស្តីបន្ទោសអ្នកដែលប្រព្រឹត្តអំពើនោះ។ ឌុច បាននិយាយថា គាត់បានរាយការណ៍ អំពីហេតុការណ៍នោះទៅថ្នាក់លើ ប៉ុន្តែមិនទទួលបានការឆ្លើយតបទេ។ ហេតុដូច្នេះ ឌុច មិនបាន ដាក់ទណ្ឌកម្មអ្នកដែលបានប្រព្រឹត្តនោះទេ ដោយគ្រាន់តែប្តូរឲ្យទៅសួរចម្លើយអ្នកផ្សេងប៉ុណ្ណោះ។ ឌុច ក៏បានស្នើផងដែរថា ប្រពន្ធរបស់កម្មាភិបាលត្រូវបានតែងតាំងជាអ្នកសួរចម្លើយអ្នកទោសស្រី ហើយសំណើនេះត្រូវបានយល់ព្រម។ ទោះជាយ៉ាងណាក៏ដោយ ប្រាក់ ខន បាននិយាយថា នារីជាអ្នកសួរចម្លើយទាំងនេះត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ហើយយ៉ាងយូរ ចាប់ពីឆ្នាំ១៩៧៧មក អ្នកទោសស្ត្រីទាំងអស់ ត្រូវសួរចម្លើយដោយបុរសវិញដដែ។

៤៥៨. ម្យ៉ាងវិញទៀត ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ណាំ ម៉ុន បានអះអាងនៅពេលស្តាប់ ចម្លើយថា គាត់ត្រូវ បានគេចាប់រំលោភ នៅពេលជាប់ឃុំនៅមន្ទីរ ស-២១ នៅឆ្នាំ១៩៧៧ ដោយសន្តិសុខម្នាក់ដែលគាត់បាន ស្គាល់នៅពេលជំនុំជម្រះក្តីឌុចនៅចំពោះមុខអ.វ.ត.ក។ ការរំលោភផ្លូវភេទត្រូវបានប្រព្រឹត្តនៅក្នុងបន្ទប់ ឃុំឃាំងមួយតែឯង នៅពេលដែលគាត់ជាប់ច្រវ៉ាក់ ហើយធ្វើឲ្យគាត់ធ្លាក់ឈាមជាច្រើនថ្ងៃជាប់គ្នា។ សន្តិសុខនោះក៏បានគំរាមថា មិនឲ្យប្រាប់ អ្នកណាទេ ប្រយ័ត្នគេសម្លាប់ចោល។ នៅក្នុងក្របខ័ណ្ឌនៃសាលក្រមរបស់ ឌុច អង្គជំនុំជម្រះសាលាដំបូងបានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកស្រី ណាំ ម៉ុន ដោយយល់ឃើញថា ភស្តុតាងដែលគាត់បានផ្តល់ជូនមិនអាចឲ្យសន្និដ្ឋានថា គាត់ត្រូវ បានឃុំខ្លួននៅមន្ទីរស-២១ ទេ'។ បន្ទាប់ពីមាន សេចក្តីសម្រេចបដិសេធបែបនេះ រឿងហេតុដែល បានរៀបរាប់ខាងលើ ដែលខុសពីរឿងហេតុដែលបាន លើកឡើងនៅក្នុងសវនាការ បានលេចឡើង ហើយបានធ្វើឲ្យសហចៅក្រមស៊ើបអង្កេតសម្រេចធ្វើការ ស្តាប់ចម្លើយសាជាថ្មី នៅក្នុងក្របខ័ណ្ឌ នៃសំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស។ បន្ទាប់ពីបានបំពេញកិច្ចស៊ើបសួរ សាជាថ្មីនេះ សហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា សេចក្តីបំភ្លឺដែលផ្តល់ដោយដើមបណ្តឹង រដ្ឋប្បវេណីរូបនេះអាចជឿទុកចិត្តបាន និងមានភាពគ្រប់គ្រាន់ តាមបទដ្ឋានតម្រូវនៅដំណាក់កាល នេះនៃនីតិវិធី។

៤៥៩. ភស្តុតាងមួយចំនួនបង្ហាញថា មានករណីរំលោភផ្លូវភេទផ្សេងទៀត ត្រូវបានប្រព្រឹត្ត នៅមន្ទីរ ស-២១ ជាពិសេស ការរំលោភដោយអ្នកសួរចម្លើយម្នាក់ឈ្មោះ ទូច ទៅលើអ្នកជាប់

ឃុំស្រីម្នាក់។ នៅក្នុងសាលក្រមនៃសំណុំរឿង ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា "អង្គហេតុនេះមិនមានភស្តុតាងបញ្ជាក់ទៅតាមបទដ្ឋានតម្រូវ ឡើយ" ។

១៤២៦. មានភស្តុតាងបង្ហាញយ៉ាងច្បាស់ថា ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការរំលោភផ្លូវភេទ ត្រូវបានប្រព្រឹត្តឡើងនៅក្នុងកាលៈទេសៈផ្សេងៗ ជាអាទិ៍ នៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ ភូមិភាគឧត្តរ ព្រៃដំរីស្រុត មន្ទីរស-២១ និងសង់ ព្រមទាំងនៅក្នុងសហករណ៍ត្រាំកក់។

១៤២៧. ចំពោះទីតាំងនីមួយៗដូចបានរៀបរាប់ខាងលើ ចារីបានប្រព្រឹត្តដោយចេតនានូវការលុកលុយរាងកាយជាលក្ខណៈផ្លូវភេទទៅលើជនរងគ្រោះ តាមវិធីបង្ខំ ដោយគ្មានការព្រមព្រៀងគ្នាពីសំណាក់ជនរងគ្រោះ ដែលចារីបានដឹងច្បាស់ ហើយធាតុផ្សំជាបរិបទនៃការរំលោភផ្លូវភេទ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបំពេញ។

១៤២៨. ផ្អែកតាមអង្គហេតុដែលបានរៀបរាប់នៅក្នុងផ្នែកស្តីអំពី "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម" នៃដីកាដំណោះស្រាយនេះ យើងឃើញថា ទំនាក់ទំនងផ្លូវភេទក្រៅអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកថាផ្ទុយទៅនឹងទស្សនៈសម្ពូហភាពរបស់ ប.ក.ក ហើយថា ជនដែលត្រូវបានចោទប្រកាន់ថា មានអំពើ "ខុសសីលធម៌)" ត្រូវបានចាត់ចូលប្រភេទ "សមាសភាពមិនល្អ" ឬ"ខ្មាំង" ដែលជារឿយៗ ត្រូវបានលត់ដំ ឬ សម្លាប់។ នៅក្នុងបរិបទនេះ កម្មាភិបាលនៃមន្ទីរសន្តិសុខទាំងនេះដឹងថា ការរំលោភផ្លូវភេទគឺជាបទល្មើសដែលខ្លួនអាចទទួលរងទណ្ឌកម្ម ឧទាហរណ៍ដូចជានៅមន្ទីរសន្តិសុខ ក្រាំងតាចាន់ជាដើម។ ជាញឹកញាប់ អ្នកដែលបានប្រព្រឹត្តអំពើរំលោភផ្លូវភេទត្រូវបានចាប់ខ្លួន នៅពេលថ្នាក់លើរបស់ពួកគេបានដឹងអំពីអំពើបទល្មើសនេះ ដូចជានៅមន្ទីរសន្តិសុខ សង់។ លើសពីនេះ ជួនកាលកម្មាភិបាល ប.ក.ក បានទទួលការណែនាំឱ្យស៊ើបអង្កេតលើករណីរំលោភផ្លូវភេទនៅតាមសន្តិសុខនានា ដូចជា នៅមន្ទីរសន្តិសុខក្រាំងតាចាន់។ មានភស្តុតាងដែលបង្ហាញថាកម្មាភិបាលបានរាយការណ៍អំពីករណីរំលោភផ្លូវភេទជូនថ្នាក់លើរបស់ខ្លួន ដោយចារីទាំងនោះត្រូវបានចាត់ទុកថាជា "ជនក្បត់" ឬ "ខ្មាំង" ដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្តីអំពីជនត្រូវចោទ នួន ជា និង អៀង សារី និង នៅក្នុងផ្នែកស្តីអំពីសហករណ៍ស្រុកត្រាំកក់។

ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន ថា៖

គោលនយោបាយជាផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ គឺបង្ការបទឧក្រិដ្ឋនេះ និងដាក់ទណ្ឌកម្មដល់ចារី។ ពិតណាស់ ទោះបីជាគោលនយោបាយនេះ មិនអាចឈានទៅដល់ការរារាំងការរំលោភផ្លូវភេទក៏ដោយ ក៏គេមិនអាចចាត់ទុកថា ការរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រើប្រាស់ដោយបក្សកុម្មុយនីស្តកម្ពុជាក្នុងការដាក់ឲ្យអនុវត្តនូវផែនការរួមឡើយ។

8. ផ្នែកសេចក្តីសម្រេចនៃដីកាដំណោះស្រាយ បានធ្វើការចោទប្រកាន់លើសហជនជាប់ចោទទាំងនោះ និងបានបញ្ជូនពួកគេទៅកាន់អង្គជំនុំជម្រះសាលាដំបូងដើម្បីធ្វើការជំនុំជម្រះលើ ឧក្រិដ្ឋកម្មនៃការរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយតាមរយៈការប្រព្រឹត្ត (តាមរយៈសហឧក្រិដ្ឋកម្មរួម) ការរៀបចំផែនការ ការញុះញង់ឲ្យប្រព្រឹត្ត ការបញ្ជា ការជួយ និងការជម្រុញ ឬការទទួលខុសត្រូវក្នុងនាមថ្នាក់លើ[9]។

9. មុនពេលដែលដីកាដំណោះស្រាយត្រូវបានចេញ ពុំមានមេធាវីការពារក្តីក្នុងក្រុមណាមួយ (ហៅកាត់រួមគ្នាថា "មេធាវីការពារក្តី") បានស្នើសុំឲ្យមានការលុបចោលនូវអង្គហេតុនៃការចោទប្រកាន់ទាំងនោះឡើយ។ មិនតែប៉ុណ្ណោះ នៅពេលដែលដីកាដំណោះស្រាយត្រូវបានចេញ មេធាវីការពារក្តីក៏ពុំបានជំទាស់ទៅនឹងការកត់សម្គាល់ឃើញ*ពីអង្គហេតុ* ដែលទាក់ទងនឹងករណីនៃការរំលោភសេពសន្ថវៈដែលរងការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ ហើយក៏ពុំបានស្នើសុំមោឃភាព ទៅលើវិការៈនៃនីតិវិធី ដូចមានចែងនៅក្នុងវិធាន ៦៧(២) នៃវិធានផ្ទៃក្នុងឡើយ។

10. នៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកាដំណោះស្រាយ មេធាវីការពារក្តី នួន ជា *ក្នុងចំណោមចំណុចនានា* បានប្តឹងឧទ្ធរណ៍លើការកំណត់ទោសព្រហ្មទណ្ឌនៃបទល្មើស ដែលចែងនៅក្នុងមាត្រា ៤-៦ នៃច្បាប់ អ.វ.ត.ក[10]។ មេធាវីការពារក្តី ខៀវ សំផន បានប្តឹងឧទ្ធរណ៍

---

[9] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៦១៣។

[10] បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/3/1**, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០, កថាខណ្ឌ ៣០-៣២, មេធាវីការពារក្តី នួន ជា ធ្វើការជំទាស់បន្ថែមថា ដីកាដំណោះស្រាយ មានកំហុសក្នុងការបញ្ជាក់ពីយុត្តាធិការរបស់សាលាក្តី ដោយសន្និដ្ឋានថាការអនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវ ដែលបានយោងនៅក្នុងច្បាប់ អ.វ.ត.ក ស្របទៅនឹងគោលការណ៍នីត្យានុកូលភាព(*ដូចជើងទំព័រខាងលើ* កថាខណ្ឌ២៤-២៦), ច្បាប់ព្រហ្មទណ្ឌក្នុងប្រទេស នៅពេលហេតុការណ៍ដែលត្រូវបានចោទ បានកើតឡើង ពុំចែងអំពីការដាក់ជាទោសព្រហ្មទណ្ឌទៅលើអំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាមឡើយ (*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៧-២៩)។ គោលការណ៍នីត្យានុ-

ដោយលើកឡើងអំពីការបំពានលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[11]។ កាលពីថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[12] និងសម្រេចថា ការរំលោភផ្លូវភេទ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ ក្នុងរយៈពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ[13] ប៉ុន្តែអាចត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ដទៃទៀត៖

> "មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតក្នុងវិសាលភាព ដែលសហមេធាវីការពារក្តី អះអាងថា ការរំលោភលើផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេក្នុងរយៈពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចដកការរំលោភផ្លូវភេទចេញពីកថាខណ្ឌ ១៦១៣ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ (ឆ) នៃដីកាដំណោះស្រាយ និងរក្សាទុកការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងកថាខណ្ឌ ១៤៣៣ នៃដីកាដំណោះស្រាយថា "អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោម

---

កូលភាព អន្តរជាតិ ពុំចែងអំពីឧក្រិដ្ឋភាពនៅក្នុងប្រទេសឡើយ (*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣៣-៣៤)។ ការដាក់ជាទោសព្រហ្មទណ្ឌដោយប្រតិសកម្ម រំលោភទៅលើគោលការណ៍នីត្យានុកូលជាតិ (*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣៥-៣៧)។

[11] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/4/3**, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៤, កថាខណ្ឌ ៣១-៣៧។ ក្រុមមេធាវីការពារក្តី ខៀវ សំផន ក៏បានលើកឡើងអំពីបញ្ហានានាទាក់ទងនឹងការបដិសេធសិទ្ធិឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានស្ថាពរ (៦៣-៦៨) ភ័ស្តុតាងពុំមានជាភាសាបារាំង និងភាសាខ្មែរ (៦៩-៧៣), កង្វះតម្លាភាពនៃសកម្មភាពរបស់សហចៅក្រមស៊ើបអង្កេត (៧៤-៨៤) និងកិច្ចស៊ើបសួរមិនបានពេញលេញ និងដោយអន្លើ (៨៥-១១៦)។

[12] ក្រុមមេធាវីការពារក្តី អៀង សារី និង អៀង ធីរិទ្ធ ជំទាស់ថាការរំលោភផ្លូវភេទ ពុំបានកើតឡើងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ទេ។ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/1/6**, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០, បណ្តឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/2/1**, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។

[13] អង្គបុរេជំនុំជម្រះ យល់ឃើញថា "ការរំលោភសេពសន្ថវៈ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមានធាតុផ្សំទាំងអស់ដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ដូចជាលក្ខខណ្ឌតម្រូវដែលជាផ្នែកមួយនៃ "ការវាយប្រហារយ៉ាងទូលំទូលាយ ឬជាប្រព័ន្ធ" និង "ការរំលោភលើផ្លូវភេទដែលច្បាប់ព្រហ្មទណ្ឌថ្នាក់ជាតិ កំណត់និយមន័យ មិនមានធាតុផ្សំនេះទេ" និងលើកឡើងបន្ថែមថា "ការរំលោភលើផ្លូវភេទតែឯកឯង មិនអាចបញ្ចូលទៅក្នុងច្បាប់អន្តរជាតិ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេ ដោយសារគោលការណ៍ទូទៅរបស់ច្បាប់ ដែលត្រូវបានទទួលស្គាល់ដោយបណ្តាប្រជាជាតិដែលមានអារ្យធម៌ខ្ពង់ខ្ពស់" និង*សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍ ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/3/15**, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១, កថាខណ្ឌ ១៥៣។

ទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត)[14]"។

**(ខ) ដំណាក់កាលជំនុំជម្រះ៖ ការកំណត់សារជាថ្មីថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការរំលោភផ្លូវភេទ ថាជាឧក្រិដ្ឋកម្មផ្សេងពីគ្នា**

11. កាលពីថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញា បានដាក់សំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់សារជាថ្មីនូវអង្គហេតុនានា ដែលបញ្ជាក់ពីការប្រព្រឹត្តិអំពើរំលោភសេពសន្ថវៈ ថា ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការរំលោភសេពសន្ថវៈ ជៀសជាងថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់នៃ អំពើអមនុស្សធម៌ដទៃទៀត[15]។ ជាការឆ្លើយតប សហមេធាវីនាំមុខក៏បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកំណត់សារជាថ្មីអំពីការរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ "ក្រោមទម្រង់ជាបទល្មើសមួយដោយឡែក"[16]។

12. កាលពីថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង នៅពេលចេញសេចក្ដីសម្រេចរបស់ខ្លួនលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ បានដាក់បញ្ចូលយ៉ាងជាក់លាក់នូវបទចោទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតដែលជាការរំលោភសេពសន្ថវៈ ដោយកម្រិតត្រឹមតែនៅសហករណ៍

---

[14] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/2/12**, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ១១(២), សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/1/26**, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ៧(២)។ *សូមមើលផងដែរ* សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/4/14**, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ២(១២)។

[15] សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពស្ថវៈ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, **E99**, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ("សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកំណត់បទចោទសាជាថ្មី") កថាខណ្ឌ ៣៣។

[16] ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, **E99/1**, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១ ("ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើសុំឱ្យកំណត់បទចោទ"), កថាខណ្ឌ ៤៥(i)។

ត្រាំកក់ មន្ទីរ ស២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំតែប៉ុណ្ណោះ[17]។ សេចក្តីសម្រេចនេះ ក៏ដាក់បញ្ចូលផងដែរនូវបទចោទនៃអំពើអមនុស្សធម៌ដទៃទៀតដែលជា "ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ" ដែលកម្រិតត្រឹមតែនៅសហករណ៍ត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ស២១ ក្រាំងតាចាន់ អូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល[18] ព្រមទាំងការធ្វើទារុណកម្ម ដែលកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ស២១ ក្រាំងតាចាន់ មន្ទីរសន្តិសុខភ្នំក្រោល និងការប្រព្រឹត្តិលើជនជាតិចាម[19]។

13. កាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើសេចក្តីជំទាស់បឋមដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ពាក់ព័ន្ធនឹងការកំណត់សារជាថ្មីនូវករណីនៃការរំលោភសេពសន្ថវៈដែលប្រព្រឹត្តនៅក្រៅបរិបទនៃការរៀបការដោយបង្ខំថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការរំលោភសេពសន្ថវៈ ក្រោមទម្រង់ជាបទល្មើសមួយដោយឡែក។ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈពាក់ព័ន្ធនឹងការកំណត់បទល្មើសនេះដោយបានសម្រេចថា អង្គជំនុំជម្រះពុំមានសិទ្ធិអំណាចដាក់បញ្ចូលអង្គហេតុ ឬបទចោទថ្មីទៅក្នុងដីកាដំណោះស្រាយ ដែលអង្គហេតុ ឬបទចោទនោះ ត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតហើយនោះ។ សេចក្តីសម្រេចនេះពុំត្រូវបានបដិសេធដោយអង្គបុរេជំនុំជម្រះឡើយ"[20]ជាពិសេសទាក់ទងនឹង "ការរំលោភផ្លូវភេទជា*គោលនយោបាយ*មួយ នៅក្នុងមន្ទីរសន្តិសុខ"[21]។ នៅក្នុងសេចក្តីសម្រេចដដែលនោះ អង្គជំនុំជម្រះសាលាដំបូង បញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងរក្សាសិទ្ធិ "ផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយបាន លុះត្រាតែ *មិនមានការដាក់បញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទ*"[22]។

---

[17] បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿង ០០២/០២), **E301/9/1.1**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤, ទំព័រ៤។

[18] *ដូចជើងទំព័រខាងលើ*។

[19] *ដូចជើងទំព័រខាងលើ* ទំព័រ៣។

[20] ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់, ឯកសារ E306, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ("អនុស្សរណៈស្តីពីអញ្ញត្រកម្ម"), កថាខណ្ឌ ៣។

[21] *ដូចជើងទំព័រខាងលើ* (គូសបញ្ជាក់បន្ថែម)។

[22] *ដូចជើងទំព័រខាងលើ*។

14. ស្រដៀងគ្នានេះផងដែរ កាលពីថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ នៅពេលដែលមានសំណើសុំឲ្យមានការតទល់គ្នារវាងសាក្សី 2-TCW-944 និងដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 ហើយនឹងដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-304 អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់នៅក្នុងអនុស្សារណៈទាក់ទងនឹងអញ្ញត្រកម្មដែលបានចេញកាលពីពេលមុន[23] ដែលបានសម្រេចពាក់ព័ន្ធនឹងសំណើសុំកំណត់ទង្វើនៃការរំលោភសេព សន្ធវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃការរំលោភសេពសន្ថវៈ ក្រោមទម្រង់ជាឧក្រិដ្ឋកម្មមួយដោយឡែក។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា៖

> "អង្គជំនុំជម្រះកត់សម្គាល់ថា ហេតុការណ៍នៃការរំលោភផ្លូវភេទអាចជាការពាក់ព័ន្ធ ក្នុងចំណោមការពាក់ព័ន្ធផ្សេងទៀត ទៅនឹងលក្ខខណ្ឌនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះបានច្រានចោលសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំបន្ថែមបទចោទស្តីពី ការរំលោភផ្លូវភេទ (ដែលបានប្រព្រឹត្តឡើងក្រៅបរិបទនៃការរៀបការដោយបង្ខំ) ដែលបានប្រព្រឹត្តនៅក្នុងមន្ទីរសន្តិ-សុខនេះ។ ត្រង់ចំណុចនេះ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា ការរំលោភផ្លូវភេទបានកើតមានឡើងនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ ក្នុងចំណោមកន្លែងផ្សេងៗដែលមានហេតុការណ៍នេះ។ ទោះបីយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា ការរំលោភផ្លូវភេទនៅក្រៅបរិបទនៃការរៀបការដោយបង្ខំ មិនអាចត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលបានប្រើប្រាស់ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីអនុវត្តគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម។ ដីកាដំណោះស្រាយក៏មិនបានចោទប្រកាន់ថា ជនជាប់ចោទមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការរំលោភផ្លូវភេទនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដោយផ្អែកទៅលើទម្រង់នៃការទទួលខុសត្រូវផ្សេងទៀតដែរ។[24]"

15. កាលពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញា ក្នុងការឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា ដែលស្នើឲ្យដាក់បន្ថែមសាក្សីចំនួន១៥រូប សម្រាប់ផ្នែកស្តីពីសហករណ៍

---

[23] *សូមមើល* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការតទល់គ្នា ជើងទំព័រ ២៣ *ដកស្រង់* អនុស្សារណៈទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ កថាខណ្ឌ ៣ ដែលបានបង្ហាញ។

[24] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឲ្យមានការតទល់គ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ជាមួយសាក្សី ស្រី ផន និងដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង និងស្នើសុំឯកសារថតសំឡេងនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សយ សែន, ឯកសារ E348/4, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការតទល់គ្នា"), កថាខណ្ឌ ១១ (សម្រង់បញ្ជាក់ខាងក្នុងត្រូវលុបចោល)។

ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ បានបញ្ជាក់ថា "ជនជាប់ចោទ មិនត្រូវបានចោទទៅលើការរំលោភផ្លូវភេទនេះទេ។[25]"

16. កាលពីថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានកត់សម្គាល់សាជាថ្មីថា "សហព្រះរាជអាជ្ញាអន្តរជាតិមិនពិចារណាលើភ័ស្តុតាងណា ដែលកម្មាភិបាលត្រូវបានគេផ្តន្ទាទោសចំពោះអំពើរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ថាជាភ័ស្តុតាងដោះបន្ទុកនោះទេ ពីព្រោះថា *ដីកាដំណោះស្រាយមិនបានចោទប្រកាន់ជនជាប់ចោទនឹងបទល្មើសរំលោភផ្លូវភេទ ដែលបានប្រព្រឹត្តក្រៅវិសាលភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ*"[26]។

**(គ) ដំណាក់កាលជំនុំជម្រះ៖ សំណើសុំបញ្ជាក់អំពីវិសាលភាពពីការចោទប្រកាន់លើអង្គហេតុ**

17. ជាបន្តមកទៀត កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ មុនពេលចាប់ផ្តើមសវនាការវគ្គជំនុំជម្រះលើមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង សហមេធាវីនាំមុខបានដាក់សារណា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងស្តីពីការបញ្ជាក់ពីវិសាលភាពនៃ សំណុំរឿង ០០២/០២ ទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[27]។

---

[25] ប្រតិចារឹក ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥, **E1/289.1**, ទំព័រ៨៣-៨៤។

[26] ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារមួយចំនួនពីសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៤ **D193/61, D319/40,** ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៦, កថាខណ្ឌ ៦ *ដកស្រង់* ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់, **E306,** ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤, កថាខណ្ឌ ៣ (គូសបញ្ជាក់បន្ថែម)។

[27] សារណារបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន៩២ នៃវិធានផ្ទៃក្នុង ស្តីពីការបញ្ជាក់ពីវិសាលភាពនៃ សំណុំរឿង ០០២/០២ ទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ, ឯកសារ **E306/7**, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ("សំណើសុំបញ្ជាក់") កថាខណ្ឌ ២៨។ សហមេធាវីនាំមុខ ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង បញ្ជាក់ថា "អង្គជំនុំជម្រះសាលាដំបូងបានទទួលបណ្តឹងជាផ្លូវការនូវការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភផ្លូវភេទ នៅសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ នៅក្នុងសំណុំរឿង ០០២/០២ និងចាត់វិធានការណាមួយដែលត្រូវបានអនុញ្ញាតដោយវិធានផ្ទៃក្នុង ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។"

18. កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ មេធាវីការពារក្តីលោក ខៀវ សំផន បានឆ្លើយតបទៅនឹងសារណានេះថា អង្គជំនុំជម្រះមិនត្រូវបានប្តឹងអំពីអង្គហេតុនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ[28]។

19. កាលពីថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ សហមេធាវីនាំមុខបានឆ្លើយតបថា "អនុស្សរណៈស្តីពីអញ្ញត្រកម្មពុំទាក់ទងការជូនដំណឹងជាក់ស្តែងអំពីការចោទប្រកាន់លើអង្គហេតុពីអំពើរំលោភសេពសន្ថវៈឡើយ[29]។ ប៉ុន្តែ អនុស្សរណៈនេះបានគូសបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិដើម្បី "ផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់ក្នុងដីកាដំណោះស្រាយ ល្គឹកណាធាតុផ្សំថ្មីនៃបទចោទពុំត្រូវបានបង្ហាញ"[30]។ សហមេធាវីនាំមុខអះអាងថា ដីកាដំណោះស្រាយក៏មិនបានចោទប្រកាន់ថាជនជាប់ចោទ "មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការរំលោភផ្លូវភេទនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដោយផ្អែកទៅ*លើទម្រង់នៃការទទួលខុសត្រូវផ្សេងទៀតដែរ*" ហើយសហមេធាវីនាំមុខក៏អះអាងថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសា-លាដំបូងស្តីពីការតទល់គ្នា ពុំធ្វើឲ្យការអានផ្ទុយទៅនឹងអ្វីដែលសហមេធាវីនាំមុខស្នើសុំ ឡើយ[31]។

20. កាលពីថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ដោយបញ្ជាក់ពីសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចំពោះ "សំណើសុំបញ្ជាក់សាជាថ្មីអំពីការចោទប្រកាន់លើអង្គហេតុ ពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈនៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ និង សខ២១"[32]។

---

[28] ចម្លើយរបស់មេធាវីការពារក្តី លោក ខៀវ សំផន ទៅនឹងសំណើសុំបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបទចោទនៃការរំលោភសេពសន្ថវៈ ឯកសារ E306/7/1 ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ ("ចម្លើយរបស់មេធាវីការពារក្តី ទៅនឹងសំណើសុំបំភ្លឺ) កថាខណ្ឌ ៨-១៥។

[29] ការឆ្លើយតបរបស់សហមេធាវីនាំមុខទៅនឹងចម្លើយរបស់មេធាវីការពារក្តី ខៀវ សំផន តបសំណើសុំការបញ្ជាក់បំភ្លឺស្តីពីការរំលោភសេពសន្ថវៈនៅក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ ឯកសារ E306/7/2 ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ("ការឆ្លើយតបនឹងសំណើសុំការបញ្ជាក់បំភ្លឺ") កថាខណ្ឌ៥។

[30] *ដូចឯកសារយោងខាងលើ* ។

[31] ការឆ្លើយតបនឹងសំណើសុំការបញ្ជាក់បំភ្លឺ កថាខណ្ឌ៦ *ដកស្រង់* ចម្លើយរបស់មេធាវីការពារក្តី លោក ខៀវ សំផន ទៅនឹងសំណើសុំបំភ្លឺ កថាខណ្ឌ ១១។

[32] សេចក្តីសម្រេចដែលរងការជំទាស់ ទំព័រ ៨។

21. កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ មេធាវីការពារក្ដី នួន ជា បានលើកឡើងពីសេចក្ដីសម្រេច ដែលអាចរងការជំទាស់នៅក្នុងសវនាការ ដើម្បីកម្រិតពីភ័ស្តុតាង ចំពោះអំពើរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំថា៖

> ដរាបណាដែលសំណើរបស់សហព្រះរាជអាជ្ញាបានយកមកពិចារណា យើងគិតថា ឯកសារដែល ថាពួកគេបានស្នើសុំមានការពាក់ព័ន្ធ ដោយមូលហេតុថា ឯកសារនោះពាក់ព័ន្ធទៅនឹងការចោទប្រ-កាន់នៅក្នុងករណីនេះ ដោយអង្គជំនុំជម្រះបានបញ្ជាក់ថ្មីៗនេះនៅក្នុងសេចក្ដីសម្រេច ឯកសារ E306/7/3។ ដូច្នេះ យើងកំពុងតែជជែកគ្នាពីការរៀបអាពាហ៍ពិពាហ៍ និងការចោទចំពោះ អំពើរំលោភសេពសន្ថវៈនៅក្នុងបរិបទមួយនេះ។ ដូច្នេះ ដើម្បីបញ្ចប់ យើងសូមឆ្លើយថា មានតែ ផ្នែកមួយចំនួន នៅក្នុងឯកសារនេះតែប៉ុណ្ណោះដែលអាចជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបទចោទ ដែលនឹងត្រូវទទួលយក[33]។

## III. ច្បាប់ដែលត្រូវអនុវត្ត

### (ក) គោលការណ៍សង្ខេបនៃបណ្ដឹងសាទុក្ខ

22. យោងតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដូចខាង ក្រោមត្រូវបានបើកផ្លូវឱ្យប្ដឹងសាទុក្ខភ្លាមៗ៖ ក-សេចក្ដីសម្រេចដែលមានអានុភាពបញ្ចប់កិច្ច ដំណើរការនីតិវិធី ។ ខ-សេចក្ដីសម្រេចអំពីការឃុំខ្លួន និងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាម ផ្លូវតុលាការអនុលោម តាមវិធាន ៨២ ។ គ-សេចក្ដីសម្រេចអំពីវិធានការការពារតាមវិធាន ២៩(៤)(គ) និង ឃ-សេចក្ដីសម្រេចស្ដីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំ ជម្រះតាមវិធាន៣៥(៦)។ សេចក្ដីសម្រេចផ្សេងទៀត អាចប្ដឹងសាទុក្ខបានតែក្នុងករណី ដែលបាន ធ្វើឡើងស្របពេលជាមួយបណ្ដឹងសាទុក្ខ ពីសាលក្រមលើអង្គសេចក្ដី។

23. អង្គជំនុំជម្រះតុលាការកំពូលបានអះអាងថា សិទ្ធិប្ដឹងសាទុក្ខ ដែលមានចែងនៅក្នុងវិធាន ១០៤(៤)(ក)នៃវិធានផ្ទៃក្នុង ធានាថា "មធ្យោបាយនៃបណ្ដឹងសាទុក្ខធ្វើឡើង នៅពេលដែលកិច្ច ដំណើរការនីតិវិធីត្រូវបានបញ្ចប់ដោយមិនទាន់ចេញសាលក្រម ដូច្នេះទើបភាគីមិនមានឱកាសដាក់

---

[33] សេចក្ដីព្រាង ប្រតិចារិក ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៦ ទំព័រ ១២ ម៉ោង ០៩.២៤.១០។

បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម"[34]។ អង្គជំនុំជម្រះតុលាការកំពូលបានបកស្រាយថា "អានុភាពនៃការបញ្ចប់កិច្ចដំណើរការនីតិវិធី"រួម បញ្ចូលសេចក្ដីសម្រេចនានាក្នុងការផ្អាកកិច្ចដំណើរការនីតិវិធីខណៈដែលពុំមានសញ្ញាណនៃការបន្តនីតិវិធីទេនោះ[35]"។

**(ខ) មូលដ្ឋានបណ្ដឹងសាទុក្ខ**

24. យោងតាមវិធាន ១០៤(១) និង ១០៥(២) នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ ដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖ ក. បញ្ហាក់អំពីកំហុសអង្គច្បាប់ និងត្រូវបង្ហាញថាកំហុសនោះបណ្ដាលឱ្យសេចក្ដីសម្រេចមានមោឃៈភាព។ ឬ ខ.បញ្ជាក់អំពីកំហុសដែលស្ដែងឡើងពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំអោយ មានការប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ។ ឬ គ. បញ្ជាក់អំពីកំហុសអង្គហេតុ និងត្រូវបង្ហាញថាកំហុសនេះ នាំអោយមានការភ័ន្តច្រឡំក្នុងការសំរេច សេចក្ដីរបស់តុលាការ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ពីមុនៗថា បណ្ដឹងសាទុក្ខភ្លាមៗអាចផ្អែកលើមូលដ្ឋាន តែមួយ ឬច្រើននៃមូលដ្ឋានដែលបានបញ្ជាក់ខាងលើ។

**(គ) ដីកាលើកលែងការចោទប្រកាន់**

25. សហចៅក្រមស៊ើបអង្កេតអាចធ្វើសេចក្ដីសម្រេច ទាក់ទងនឹងអង្គហេតុទាំងអស់ដែលបានប្ដឹងមកកាន់ខ្លួន និងការកំណត់ប្រភេទបទល្មើសដែលពាក់ព័ន្ធ ដែលស្នើឡើងដោយសហ ព្រះរាជអាជ្ញាដោយ (១)ត្រូវបញ្ជូនជនត្រូវចោទទៅជំនុំជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីបានចោទ

---

[34] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ឯកសារ E163/5/1/13 ចុះថ្ងៃ ០៨ ខែកុម្ភៈ ឆ្នាំ២០១៣ កថាខណ្ឌ ២២ *ដកស្រង់* សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឯកសារ E95/8/1/4 ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ កថាខណ្ឌ៩។

[35] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ឯកសារ E138/1/7 ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ កថាខណ្ឌ១៥ ដកស្រង់ការបញ្ជាក់ពី សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឯកសារ E95/8/1/4 ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ កថាខណ្ឌ៩។

ប្រកាន់ពួកគេ ឬ (២) ចេញដីកាលើកលែងការចោទប្រកាន់ ចំពោះអង្គហេតុទាំងមូល ឬតាមផ្នែក[36]។ វិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង ចែងថា "ដីកាដំណោះស្រាយបើកផ្លូវឲ្យប្ដឹងឧទ្ធរណ៍ ដូចមានចែងក្នុងវិធាន ៧៤ នៃវិធានផ្ទៃក្នុង"។

26. មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថា ចៅក្រមស៊ើបសួរ បិទការស៊ើបសួរ តាមរយៈដីកាបញ្ជូនរឿងជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់។ មាត្រានេះចែងថា "ដីកាលើកលែងការចោទប្រកាន់" អាចចេញបាន ប្រសិនបើ និង/ឬ នៅពេលដែល "អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ" ឬ "គ្មានភ័ស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ"។ យោងតាមមាត្រា ២៧៧ "ដីកាលើកលែងការចោទប្រកាន់" អាចប្ដឹងឧទ្ធរណ៍បាន។

27. ស្រដៀងគ្នានេះដែរ វិធាន ៦៧(៣) នៃវិធានផ្ទៃក្នុង ចែងថា "ដីកាលើកលែងការចោទប្រកាន់" ត្រូវបានចេញដោយសហចៅក្រមស៊ើបអង្កេត ប្រសិនបើ និងនៅពេលដែល "អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ" ឬ "ពុំមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ"[37]។

28. វិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង ចែងថា "ដីកាដំណោះស្រាយ ត្រូវតែមានសំអាងហេតុ។ ដីកានេះអាចជាដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះចំពោះអំពើមួយចំនួន ឬប្រឆាំងនឹងបុគ្គលមួយចំនួន និងអាចជាដីកាលើកលែងចោទប្រកាន់ចំពោះករណីដទៃទៀត"។

29. យោងតាម វិធាន ៧៤(៤)(ច) នៃវិធានផ្ទៃក្នុង ដើមបណ្ដឹងរដ្ឋប្បវេណីអាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេត "ក្នុងករណីដែលសហព្រះរាជអាជ្ញាធ្វើបណ្ដឹងឧទ្ធរណ៍ដែរ"។

**(ឃ) ចៅក្រមសម្រេចតែលើអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (*Saisine in rem*)**

---

[36] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យធ្វើការបំភ្លឺអំពីបទចោទ, **D198**, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

[37] *សូមមើលបន្ថែម* ដីកាលើកលែងការចោទប្រកាន់ HISENE HABRE ។

30. វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង ចែងថា "សាលក្រម ត្រូវតែសម្រេចត្រឹមអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ អង្គជំនុំជម្រះ អាចផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទឡើយ"[38]។ លើសពីនេះ វិធាន ៩៨(៣) នៃវិធានផ្ទៃក្នុង ចែងថា "អង្គជំនុំជម្រះត្រូវពិនិត្យថាតើអំពើនោះជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ និងថាតើជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មនោះដែរ ឬទេ"។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងនៅក្នុងសាលក្រម ឌុច ថា៖

> "៤៩៣. ភាគីនានាមិនបានតវ៉ាទៅនឹងវិធាន៩៨(២) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យមានការផ្លាស់ប្តូរការកំណត់បទចោទចំពោះបទល្មើស និងទម្រង់នៃការទទួលខុសត្រូវដែលរួមបញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែនោះទេ។ ទោះបីជាបទប្បញ្ញត្តិនានានៅក្នុងប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជា មិនមានចែងយ៉ាងច្បាស់ទាក់ទងនឹងការផ្លាស់ប្តូរទម្រង់នៃការទទួលខុសត្រូវក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថាការផ្លាស់ប្តូរការកំណត់បទចោទប្រកាន់នេះត្រូវបានអនុញ្ញាតផ្អែកតាមវិធាន ៩៨(២)។
>
> ៤៩៤. ទោះបីជាយ៉ាងណាក៏ដោយ វិធាន ៩៨(២)នៃវិធានផ្ទៃក្នុងកំណត់ថា ការកែប្រែការកំណត់បទចោទឡើងវិញ ដោយអង្គជំនុំជម្រះត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណាដែលមានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែប៉ុណ្ណោះ។ ការធ្វើដូច្នេះ ស្របគ្នានឹងសមត្ថកិច្ចដែលបានផ្តល់ទៅឲ្យអង្គជំនុំជម្រះសាលាដំបូងនៅក្នុងប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្នុងប្រព័ន្ធច្បាប់បារាំងដែលច្បាប់កម្ពុជាយកជាគំរូ។ អង្គជំនុំជម្រះយល់ឃើញថា បទប្បញ្ញត្តិនៃវិធាន៩៨(២) នៃវិធានផ្ទៃក្នុងដែលចែងថា មិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទនោះ គឺជាការលើកឡើងជាថ្មីនៃការកំណត់យ៉ាងច្បាស់ដែលមានន័យថា ការផ្លាស់ប្តូរការកំណត់បទចោទថ្មីណាមួយមិនត្រូវធ្វើឲ្យលើសពីអង្គហេតុទាំងឡាយណាដែលមានបង្ហាញនៅក្នុងឯកសារចោទប្រកាន់នោះទេ។
>
> ៤៩៥. ដូចគ្នានេះដែរ វិធានរបស់តុលាការ ICC បានអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងផ្លាស់ប្តូរការកំណត់បទចោទប្រកាន់ បន្ទាប់ពីពេលចាប់ផ្តើមដំណើរការនីតិវិធីជំនុំជម្រះ។

[38] គូសបញ្ជាក់បន្ថែម។

ទោះបីជាយ៉ាងណាក៏ដោយ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិមិនអចិន្ត្រៃយ៍នានា ជាទូទៅ អង្គជំនុំជម្រះសាលាដំបូងតម្រូវឲ្យធ្វើការផ្លាស់ប្តូរជាផ្លូវការ នូវបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនៅពេលដែលអង្គហេតុបង្ហាញថា ជនជាប់ចោទបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរផ្សេងមួយទៀត ឬច្រើនដែលបទល្មើសទាំងនោះមិនបានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ការផ្លាស់ប្តូរការកំណត់បទចោទកើតចេញពីរចនាសម្ព័ន្ធខុសគ្នាជាច្រើន រវាងតុលាការព្រហ្មទណ្ឌអន្តរជាតិមិនអចិន្ត្រៃយ៍នានា និង អ.វ.ត.ក ដែលយន្តការនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មិនអចិន្ត្រៃយ៍មួយចំនួន ដែលផ្អែកលើច្បាប់ កុំមិនឡូ (Common Law) មិនមានលក្ខណៈដូចគ្នានឹងយន្តការរបស់ អ.វ.ត.ក ដែលផ្អែកលើច្បាប់ស៊ីវិល (Civil Law) នោះទេ។ ខុសពីតុលាការ ICTY និងតុលាការ ICTR គ្មានយន្តការណាមួយនៅក្នុងអ.វ.ត.ក អនុញ្ញាតឲ្យភាគីនានា ឬអង្គជំនុំជម្រះ ធ្វើការកែប្រែជាផ្លូវការលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ មូលដ្ឋាននៃការផ្លាស់ប្តូរការកំណត់បទចោទនៅ អ.វ.ត.ក គឺមានចែងនៅក្នុងវិធាន ៩៨(២) នៃវិធានផ្ទៃក្នុងដែលចែងយ៉ាងច្បាស់អំពីយថាភាពនេះ ដោយគោរពទៅតាមការធានាឲ្យមានការជំនុំជម្រះដោយយុត្តិធម៌។

៤៩៦. ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា វិធាន ៩៨(២)នៃវិធានផ្ទៃក្នុងអាចអនុញ្ញាតឲ្យអង្គជំនុំជម្រះ ផ្លាស់ប្តូរការកំណត់បទចោទដែលមានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ដើម្បីឲ្យស្របជាមួយនឹងទម្រង់នៃការទទួលខុសត្រូវថ្មីមួយ ប្រសិនបើមានការផ្លាស់ប្តូរការកំណត់បទចោទ។ នៅពេលមានការផ្លាស់ប្តូរការកំណត់បទចោទ អង្គជំនុំជម្រះត្រូវតែធានាផងដែរថា (i) មិនមានការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និង (ii) ទម្រង់នៃការទទួលខុសត្រូវថ្មីនោះ អាចយកមកអនុវត្តបាននៅ អ.វ.ត.ក។ (ការដកស្រង់ខាងក្នុងត្រូវលប់ចេញតែមានការគូសបញ្ជាក់បន្ថែម)។

31. វិធាន ៩៨(៦) នៃវិធានផ្ទៃក្នុង ចែងថា “នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា អំពើដែលកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនមានភស្តុតាងបង្ហាញពិតប្រាកដ ឬយល់ឃើញថាជនជាប់ចោទមិនមានពិរុទ្ធភាពក្នុងអំពើទាំងនោះទេ ជនជាប់ចោទត្រូវបានរួចផុតពីបទចោទ”។ វិធាន ៩៨(៧) នៃវិធានផ្ទៃក្នុង ចែងថា “នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា បទល្មើសដែល

កំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ នោះអង្គជំនុំជម្រះត្រូវសម្រេចថា គ្មានសមត្ថកិច្ចទៅលើករណីនោះទេ"។

32. អង្គជំនុំជម្រះតុលាការកំពូលបានថែងថា អង្គជំនុំជម្រះសាលាដំបូង "មានកាតព្វកិច្ចសម្រេចលើបញ្ហាដែលពុំទាន់បានជំនុំជម្រះរួចនៅចំពោះមុខខ្លួន ដូច្នេះកិច្ចដំណើរការនីតិវិធីលើបទចោទព្រហ្មទណ្ឌត្រូវបានសម្រេចលើអង្គសេចក្តី ឬត្រូវបដិសេធចោល"[39]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ទៀតថា តុលាការត្រូវ "ដោះស្រាយបណ្តឹងឱ្យអស់"[40]។

**(ង) ការកំណត់បទចោទឧក្រិដ្ឋកម្ម**

33. វិធាន ៩៨(៣) នៃវិធានផ្ទៃក្នុង ចែងថា "អង្គជំនុំជម្រះត្រូវពិនិត្យថា តើអំពើនោះជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ និងថា តើជនជាប់ចោទបានប្រព្រឹត្តអំពើនោះដែរឬទេ"។ វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង ចែងថា "សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប៉ុណ្ណោះ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ"។

34. កាលពីថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ សម្លេងភាគច្រើនរបស់ចៅក្រមអង្គបុរេជំនុំជម្រះបានអះអាងពីភាពខុសគ្នារវាង "ការកំណត់បទចោទទៅលើអង្គហេតុ" និង "វិសាលភាពនៃការស៊ើបអង្កេត"[41]។

35. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ទៀតថា អង្គជំនុំជម្រះសាលាដំបូង រក្សាសិទ្ធិ "ផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយបាន លុះត្រាតែ *មិនមានការដាក់បញ្ចូល*

---

[39] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ឯកសារ E284/4/8 ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ("សេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី") កថាខណ្ឌ ៦២។

[40] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី *ដើងទំព័រ* ១៧៦។

[41] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [កោសលប់] ប្រឆាំងនឹងដីកាសហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់[កោសលប់]ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ឯកសារ D134/1/10 ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ៤៤-៤៥, ៤៧។

*នូវធាតុផ្សំថ្មីនៃបទចោទ*”[42]។ អង្គជំនុំជម្រះតុលាការកំពូលបានអះអាងថា អង្គជំនុំជម្រះសាលាដំបូង “មិនត្រូវបានចងកាតព្វកិច្ចដោយការកំណត់បទចោទដែលបានធ្វើឡើងដោយអង្គបុរេជំនុំជម្រះឡើយ”[43]។

**(ច) ការកំណត់អំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការរំលោភសេពសន្ថវៈ**

36. កាលពីថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ក្នុងករណីសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកំណត់ករណីនៃការរំលោភសេពសន្ថវៈមួយដែលបានកើតឡើងនៅមន្ទីរសន្តិសុខ ស-២១[44] ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទារុណកម្ម៖

> “ទោះបីជាបទល្មើសការរំលោភលើផ្លូវភេទ គឺជាបទល្មើសដាច់ដោយឡែក និងត្រូវបានគេទទួលស្គាល់ទាំងនៅក្នុងច្បាប់ អ.វ.ត. និងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ក៏មិនមានការជំទាស់នោះទេ ដែលថាការរំលោភលើផ្លូវភេទ អាចបង្កើតបានជាការធ្វើទារុណកម្ម នៅពេលដែលធាតុផ្សំផ្សេងៗទៀតនៃបទល្មើសការធ្វើទារុណកម្មត្រូវបានបំពេញ (ផ្នែក ២.៥.៣.៧)។ អង្គជំនុំជម្រះយល់ឃើញថា អំពើដែលបានបង្ហាញនៅក្នុងដីការបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែដែលបង្កើតបានជាការរំលោភលើផ្លូវភេទ គឺវាបានបំពេញយ៉ាងច្បាស់នូវធាតុផ្សំផ្លូវច្បាប់ទាំងបទល្មើសការរំលោភលើផ្លូវភេទ និងការធ្វើទារុណកម្ម។ លើសពីនេះទៀត អង្គជំនុំជម្រះក៏បានវាយតម្លៃទៅលើភស្តុតាងដែលអាចជឿជាក់បាន ដើម្បីគាំទ្រចំពោះការចោទប្រកាន់នេះផងដែរ (ផ្នែក ២.៤.៤.១.១)។ អង្គជំនុំជម្រះយល់ឃើញថា ករណីការរំលោភលើផ្លូវភេទនេះ បង្កើតឲ្យ

---

[42] ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់, ឯកសារ E306, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ (“អនុស្សរណៈស្តីពីអញ្ញត្រកម្ម”), កថាខណ្ឌ ៣។

[43] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវ ស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឯកសារ E95/8/1/4 ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ កថាខណ្ឌ ១០។ *See further*, Cour de Cassation, Cass. Crim., 22 April 1986, Bulletin Criminel, No. 136: “[I]l appartient aux juridictions correctionnelles de modifier la qualification des faits et de substituer une qualification nouvelle à celle sous laquelle ils leur étaient déférés […] à la condition qu'il ne soit rien changé ni ajouté aux faits de la prévention et que ceux-ci restent tels qu'ils ont été retenus dans l'acte de saisine. ”

[44] សាលក្រម កថាខណ្ឌ ២៤៦។

មានភាពធ្ងន់ធ្ងរនៃការធ្វើទារុណកម្មរយៈពេលយូរ និងមានភាពព្រៃផ្សៃមុនពេលដែលគាត់ត្រូវបានគេយកទៅសម្លាប់ ដូច្នេះ ចរិតលក្ខណៈនៃអំពើនេះបង្កើតបានជាបទល្មើសការធ្វើទារុណកម្ម[45]។"

37. កាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ក្នុងករណីសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលមិនផ្លាស់ប្តូរការកំណត់បទចោទនោះទេ៖

"អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អំពើរំលោភលើផ្លូវភេទ គឺជាបទល្មើសមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយយោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងកំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការស្រូបបញ្ចូលបទរំលោភលើផ្លូវភេទដែលជាបទល្មើសដាច់ដោយឡែកមួយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងជាតិ ទៅក្នុងបទធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងជាតិ។ ទោះជាយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសទេ ក្នុងការសន្និដ្ឋានថា ករណីនៃការរំលោភលើផ្លូវភេទមួយដែលស្ថិតក្រោមនិយមន័យនៃអំពើទារុណកម្ម ដែលមានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ មានចែងក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ប្រឆាំងនឹងអំពើទារុណកម្ម។ លើសនេះទៅទៀត ដោយសារថា ការរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនត្រូវបានចែងច្បាស់លាស់នាពេលនោះ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសទេ នៅពេលដែលខ្លួនមិនបានសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាទៅលើជនជាប់ចោទ ពីបទធ្វើទារុណកម្ម ជាមួយនឹងបទរំលោភលើផ្លូវភេទដែលជាបទល្មើសដាច់ដោយឡែកពីគ្នា នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[46]។"

38. កាលពីថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ក្នុងករណីសំណុំរឿង ០០២ នៅពេលដែលអង្គបុរេជំនុំជម្រះធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការកំណត់អំពើនៃការរំលោភផ្លូវភេទ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការរំលោភផ្លូវភេទដែលជាឧក្រិដ្ឋកម្មដាច់ដោយ ឡែក អង្គបុរេជំនុំជម្រះបានសម្រេចថា៖

"អង្គបុរេជំនុំជម្រះយល់ឃើញថា ក.ស.ច.ស មានការភ័ន្តច្រឡំក្នុងការចោទប្រកាន់ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដែលមានរៀបរាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចលុប "ការរំលោភផ្លូវភេទ" ចេញពីកថាខណ្ឌ ១៦១៣ នៃដីកាដំណោះស្រាយ (ឧក្រិដ្ឋកម្ម

[45] សាលក្រម កថាខណ្ឌ ៣៦៦។

[46] ឌុច សាលដីកា កថាខណ្ឌ ២១៣។

ប្រឆាំងមនុស្សជាតិ កថាខណ្ឌ(ញ))។ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះយល់ស្របជាមួយសហចៅក្រមស៊ើបអង្កេតដែលថា អង្គហេតុនានាដែលចាត់ទុកការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងអំពើអមនុស្សធម៌ផ្សេងៗទៀត ហើយអាស្រ័យហេតុនេះ អង្គហេតុទាំងនេះត្រូវបានចោទប្រកាន់ជាបទឧក្រិដ្ឋទាំងនេះ[47]។"

39. នៅក្នុងសេចក្តីសម្រេចដូចគ្នានេះដែរ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា៖

"ប្រការដែលតម្រូវថា ប្រភេទរងនីមួយៗនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" បង្ហាញពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលតាមច្បាប់អន្តរជាតិ គឺត្រូវបង្ហាញប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នោះជាការឥតប្រយោជន៍ទេ។ មានន័យថា ការប្រព្រឹត្តដែលអាចត្រូវបានចាត់ទុកជាបទល្មើសអន្តរជាតិតាមទំហំនៃបទល្មើសនោះ ដោយមិនពាក់ព័ន្ធនឹងករណីដែលថា តើការប្រព្រឹត្តនោះត្រូវ ឬមិនត្រូវបានចាត់ទុកជាបទល្មើសមួយជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" មួយទេ។ សម្រាប់សំអាងហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌតម្រូវដែលចាត់ទុកថាបទល្មើសត្រូវភ្ជាប់ជាមួយនឹងប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នោះ ហើយមិនភ្ជាប់ជាមួយការប្រព្រឹត្តជាមូលដ្ឋានដែលបង្កើតជាអំពើអមនុស្សធម៌ផ្សេងៗទៀត[48]។"

**(ឌ) ការជូនដំណឹងដល់ជនជាប់ចោទ**

40. វិធាន ៦៧ (២) នៃវិធានផ្ទៃក្នុងចែងថា "ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបញ្ជាក់អំពីអត្តសញ្ញាណរបស់ជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទបញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បើពុំនោះសោត ដីកានេះត្រូវចាត់ទុកជាមោឃៈដោយកំហុសនីតិវិធី។ វិធាន ៦៧ (៤) បានចែងថា៖ "ដីកាដំណោះស្រាយត្រូវតែមានសម្អាងហេតុ។ ដីកានេះអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំពោះអំពើមួយចំនួន ឬប្រឆាំងនឹងបុគ្គលមួយចំនួន និងអាចជាដីកាលើកលែងចោទប្រកាន់ចំពោះករណីដទៃទៀត។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា៖

[47] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/3/15 ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១៥៤។

[48] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/3/15 ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១៥៦។

"ដូចច្បាប់យុត្តិសាស្ត្រនេះបានកត់សម្គាល់ គឺថាក្រៅពីមូលដ្ឋាននៃសំណុំរឿងប្រឆាំងនឹងជនជាប់ចោទ ដីកាដំណោះស្រាយ មានគោលបំណងជូនដំណឹងដល់ជនជាប់ចោទឲ្យបានដឹងអំពីសំណុំរឿងប្រឆាំងមកលើខ្លួន និងដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ (ពិសេសគឺ សិទ្ធិរបស់ជនជាប់ចោទក្នុងការបានដឹងអំពីប្រភេទនៃបទល្មើស និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន និងមានពេលវេលា មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការការពារខ្លួន)។ សិទ្ធិនេះក្លាយទៅជាកាតព្វកិច្ចមួយដែលតម្រូវឲ្យអង្គហេតុសំខាន់ៗ ដែលជាមូលដ្ឋាននៃការចោទប្រកាន់ដែលនឹងត្រូវដាក់បញ្ចូលទៅក្នុងដីកាដំណោះស្រាយ ត្រូវមានភាពលម្អិតជាក់លាក់គ្រប់គ្រាន់ ដើម្បីឲ្យជនជាប់ចោទដឹងច្បាស់អំពីប្រភេទនៃបទល្មើស និងមូលដ្ឋាននៃការចោទប្រកាន់មកលើខ្លួន។ ត្រង់នេះអាចធ្វើឲ្យជនជាប់ចោទមានលទ្ធភាពរៀបចំការពារខ្លួនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល[49]។"

41. កាលពីថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ខៀវ សំផន ទាក់ទងនឹងយុត្តាធិការទៅលើ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការនិរទេស។ ការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងអំពីលក្ខណៈគ្រប់គ្រាន់នៃការជូនដំណឹងទៅកាន់ជនជាប់ចោទ មានដូចខាងក្រោម៖

"អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្តី ខៀវ សំផន អាចចូលពិនិត្យមើលសំណុំរឿងទាំងមូល ហើយបានទទួលការជូនដំណឹងអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២។ ចាប់តាំងពីដើមដំបូងនៃសំណុំរឿង និងជាពិសេសចាប់តាំងពីចាប់ផ្តើមកិច្ចស៊ើបសួរដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ បានផ្តល់អំណាចដល់សហចៅក្រមស៊ើបអង្កេត ពួកគេទាំងពីរត្រូវបានជូនដំណឹងជាផ្លូវការថា អំពើដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវទទួលការកំណត់ប្រភេទនៃបទចោទ ដែលរួមមាន "ការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ [...]។

អង្គជំនុំជម្រះកត់សម្គាល់ថា ក.ស.ព បានយោងយ៉ាងច្បាស់លាស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរអំពីការនិរទេសជនជាតិវៀតណាម។ បន្ថែមពីលើនេះ ការពិនិត្យមើលទៅលើដីកាដំណោះស្រាយបង្ហាញថា ជនជាប់ចោទត្រូវបានចោទប្រកាន់ពីការនិរទេស ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពាក់ព័ន្ធទៅនឹងទីតាំងដែលត្រូវបានកំណត់អត្តសញ្ញាចំនួនបីគឺ៖ ព្រៃវែង ស្វាយ

[49] សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី(អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ),ឯកសារ E122, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើបទឧក្រិដ្ឋតាមច្បាប់ជាតិ"), កថាខណ្ឌ ១៨។

រៀង និងសហករណ៍ត្រាំកក់។ ដីកាដំណោះស្រាយបានបញ្ជាក់ច្បាស់ថា "ប្រជាជនវៀតណាមក្នុងចំនួនដ៏ច្រើនដែលរស់នៅក្នុងប្រទេសកម្ពុជាត្រូវបានបង្ខំឱ្យចាកចេញពីទីកន្លែងដែលពួកគេកំពុងរស់នៅស្របច្បាប់ ហើយឆ្លងដែនទៅកាន់ប្រទេសវៀតណាម។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថាជនជាប់ចោទទទួលបានការជូនដំណឹងពីវិសាលភាពនៃកិច្ចស៊ើបសួរ និងជាពិសេសគឺឧក្រិដ្ឋកម្មនៃការនិរទេសប្រជាជនវៀតណាមទៅប្រទេសវៀតណាមដែលស្ថិតនៅក្នុងវិសាលភាពនេះដែរ។[50]"

### *(ឍ)* សិទ្ធិក្នុងការប្តឹង (*Locus standi*) របស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយ

42. វិធាន ២១(១) នៃវិធានផ្ទៃក្នុង ចែងថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង"។

43. យោងតាមវិធាន ១០៥(២) ដែលអានភ្ជាប់នឹង វិធាន១០៤(៤)(ក) នៃវិធានផ្ទៃក្នុង សិទ្ធិក្នុងការប្តឹងសាទុក្ខ ត្រូវទទួលយកពីភាគីដែលមានបំណងប្តឹងសាទុក្ខជំទាស់នឹងសាលក្រមរបស់អង្គជំនុំជម្រះដោយផ្អែកទៅលើមូលដ្ឋានជាក់លាក់ណាមួយ។ អង្គជំនុំជម្រះតុលាការកំពូលបានបកស្រាយបន្ថែមក្នុងវិធាន១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ទៀតថា "ដោយវិធាននេះមានលក្ខណៈអព្យាក្រិត្យ និងបានផ្តល់សិទ្ធិក្នុងការដាក់ពាក្យបណ្តឹងសាទុក្ខដល់ភាគីណាមួយ ដែលមានផលប្រយោជន៍ផ្លូវច្បាប់ក្នុងការធ្វើបណ្តឹងសាទុក្ខលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានអនុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី[51]។"

---

[50] សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តីទាក់ទងនឹងយុត្តាធិការទៅលើការនិរទេស ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E306/5 ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ("សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តីទាក់ទងនឹងយុត្តាធិការទៅលើការនិរទេស") កថាខណ្ឌ ៧-៨។

[51] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឯកសារ E95/8/1/4 ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ កថាខណ្ឌ៩។

44. យោងតាមវិធាន ១០៥(១)(គ) នៃវិធានផ្ទៃក្នុង សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានកម្រិត៖ "បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចត្រូវបានដាក់ដោយ [...] ដើមបណ្តឹងរដ្ឋប្បវេណីដែលអាចប្តឹងសាទុក្ខការសម្រេច ស្តីពីសំណង។ នៅពេលដែលសហព្រះរាជអាជ្ញា បានធ្វើបណ្តឹងសាទុក្ខរួចហើយ ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យបណ្តឹងប្រឆាំងនឹងសាលក្រមបាន។ ដើមបណ្តឹងរដ្ឋប្បវេណីមិនអនុញ្ញាតឲ្យធ្វើបណ្តឹងសាទុក្ខលើសេចក្តីសម្រេចផ្តន្ទាទោសបានឡើយ។"

45. សិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវបានទទួលស្គាល់ដោយជំនុំជម្រះតុលាការកំពូល[52]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ទោះបីជាបទបញ្ញត្តិជាធរមាន ជាទូទៅ បានផ្តល់ឲ្យ "ភាគី" នូវបុព្វសិទ្ធិនីតិវិធីក៏ដោយ ក៏បុព្វសិទ្ធិនេះ គប្បីត្រូវបានសន្មត់ថា មានចំពោះគ្រប់ភាគីទាំងអស់នៅក្នុងការជំនុំជម្រះ ដរាបណា ពុំមានការចែងជាក់លាក់អំពីមុខងាររបស់ភាគី និងពុំមានការរិតត្បិតជាក់លាក់នោះឡើយ[53]។"

46. វិធាន ២៣ ស្ទួនបួន នៃវិធានផ្ទៃក្នុង ចែងថា "នៅពេលដែលអង្គជំនុំជម្រះរកឃើញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះអាចសម្រេចផ្តល់ឲ្យតែសំណងផ្លូវចិត្ត និងជាសមូហភាពទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ តាមគោលបំណងនៃវិធានទាំងនេះ សំណងផ្លូវចិត្ត និង

---

[52] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F10/2** ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៥-១៦។ *សូមមើលបន្ថែម* ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅក្នុង *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo* សំណុំរឿងលេខ ICC-01/04-01/06-2958 ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១០ (ភាសាអង់គ្លេស)។ *សូមមើលផងដែរ* ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅក្នុង *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo* សំណុំរឿងលេខ ICC-01/04-01/06-2951 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៥ ៖ "អនុលោមតាមវិធាន ៩១(១) នៃវិធាននីតិវិធី និងភ័ស្តុតាង និងពាក់ព័ន្ធនឹងវិធាន ៩១(២), ៩២(៥) និង (៦) នៃវិធាននីតិវិធី និងភ័ស្តុតាង អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ជនរងគ្រោះអាចចូលរួមក្នុងបណ្តឹងសាទុក្ខទាំងនេះបាន ទៅតាមលក្ខណៈដូចតទៅ៖ អ្នកតំណាងផ្លូវច្បាប់របស់ជនរងគ្រោះ VOI និង V02 អាចបង្ហាញមតិ និងកង្វល់របស់ជនរងគ្រោះ ពាក់ព័ន្ធនឹងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងបញ្ហានេះលើបណ្តឹងសាទុក្ខ ដោយការដាក់សេចក្តីសន្និដ្ឋានរួមទៅលើឯកសារបីដើម្បីគាំទ្រដល់បណ្តឹងសាទុក្ខ"។

[53] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F10/2** ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៤។

សមូហភាពគឺជាវិធានការទាំងឡាយដែល៖ ក) ទទួលស្គាល់នូវការខូចខាតដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងដោយសារការប្រព្រឹត្តនូវបទឧក្រិដ្ឋរបស់ជនជាប់ចោទដែលត្រូវបានផ្តន្ទាទោស"។

47. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា នៅក្នុងបរិបទ អ.វ.ត.ក ការបញ្ជាក់ច្បាស់លាស់អំពីការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនេះ គឺពាក់ព័ន្ធទៅទៀតជាមួយនឹងការសម្រេចជាស្ថាពរទៅលើការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអាចឱ្យជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបានដឹងអំពីវិសាលភាពនៃសំណុំរឿងដែលខ្លួនបានទទួល និងបទល្មើសជាក់លាក់ដែលត្រូវជំនុំជម្រះ[54]។

48. អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា "គោលបំណងនៃការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក មានពីរចំណុច៖ ជាទូទៅ ក្នុងគោលបំណងដើម្បី "គាំទ្រការចោទប្រកាន់របស់អយ្យការ" ក៏ប៉ុន្តែ ក៏ "ដើម្បីទាមទារសំណងរដ្ឋប្បវេណីផងដែរ"[55]។

---

[54] ឯកសារ E122 *ជើងទំព័រ* ៣៥។

[55] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ F10/2 ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១២។

## IV. សេចក្តីសង្ខេបអំពីនិត្តិករណ៍

49. សហមេធាវីនាំមុខចោទប្រកាន់ថា ដីកាសម្រេចដែលរងការជំទាស់ បង្កើតបានជាការបញ្ចប់កិច្ចដំណើរការនីតិវិធី នៅក្នុងសំណុំរឿង០០២/០២ ទាក់ទងការចោទប្រកាន់ពីអង្គហេតុនៃអំពើនៃការរំលោភផ្លូវភេទ នៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខស២១។ សហមេធាវីនាំមុខចោទប្រកាន់តាមមូលដ្ឋានចំនួនពីរនៃបណ្តឹងឧទ្ធរណ៍ (១) កំហុសដែលអាចមើលឃើញ ក្នុងការប្រើប្រាស់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្កជាព្យសនកម្មចំពោះដើម បណ្តឹងរដ្ឋប្បវេណី និង (២) កំហុសអង្គច្បាប់ដែលបណ្តាលមកពីការអនុវត្តច្បាប់មិនត្រឹមត្រូវនៅក្នុងបរិបទ អ.វ.ត.ក។

## V. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

50. សហមេធាវីនាំមុខអះអាងថា ការចេញដីកាសម្រេចដែលរងការជំទាស់ មានផលប៉ះពាល់ធ្វើឲ្យបញ្ចប់កិច្ចដំណើរការនីតិវិធី ទាក់ទងនឹងការចោទប្រកាន់លើអង្គហេតុនៃការរំលោភផ្លូវភេទក្រៅបរិបទនៃការរៀបការដោយបង្ខំ ដែលតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីដាក់បណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំនេះ ក្នុងនាមជាភាគីមួយនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ សហមេធាវីនាំមុខសូមបកស្រាយដូចតទៅនេះ៖

### ក. ការបញ្ចប់កិច្ចដំណើរការនីតិវិធី

**(១) ហេតុអ្វីទើបសហមេធាវីនាំមុខចាត់ទុកថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយកការចោទប្រកាន់ពីអង្គហេតុ**

51. ដូចដែលបានបង្ហាញនៅក្នុងប្រវត្តិនីតិវិធី មេធាវីការពារក្តីបានទទួលការជូនដំណឹងអំពីការចោទប្រកាន់ដែលអាចមានពីបទ "រំលោភផ្លូវភេទ" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យ៉ាងហោចណាស់តាំងពីខែធ្នូ ឆ្នាំ២០០៩[56] ហើយនឹងការចោទប្រកាន់ទៅលើអង្គហេតុទាំងអស់នៃករណីរំលោភផ្លូវ

[56] កំណត់ហេតុសួរចម្លើយជនត្រូវចោទ, ឯកសារ **D275**, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, កថាខណ្ឌ ១១។ កំណត់ហេតុសួរចម្លើយជនត្រូវចោទ, ឯកសារ **E3/576**, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩, កថាខណ្ឌ ១០។

ភេទដែលស្ថិតក្រៅបរិបទនៃការរៀបការដោយបង្ខំ តាំងពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក្នុងខែកក្កដា ឆ្នាំ២០០៧ មក[57]។

52. ការចោទប្រកាន់ផ្នែកអង្គហេតុមួយចំនួននៃការរំលោភផ្លូវភេទ ដែលលេចឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេត ត្រូវបានដាក់បញ្ចូលទៅក្នុងដីកាដំណោះស្រាយ រួមទាំង មន្ទីរសន្តិសុខស២១[58] មន្ទីរសន្តិសុខសង់[59] មន្ទីរសន្តិសុខក្រាំងតាចាន់[60] មន្ទីរសន្តិសុខភូមិភាគឧត្តរ[61] និងមន្ទីរសន្តិសុខស្រុកក្រូចឆ្មារ[62]។ ការសន្និដ្ឋានដែលធ្វើឡើងនៅក្នុងដីកាដំណោះស្រាយ ទាក់ទងនឹងការចោទប្រកាន់ពីអង្គហេតុទាំងអស់នេះ មានដូចតទៅ៖

ផ្អែកតាមអង្គហេតុដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី "ការកត់សម្គាល់ឃើញអំពីអង្គហេតុ នៃឧក្រិដ្ឋកម្ម" មានភស្តុតាងបង្ហាញយ៉ាងច្បាស់ថា ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរំលោភផ្លូវភេទ ត្រូវបានប្រព្រឹត្តឡើងនៅក្នុងកាលៈទេសៈផ្សេងៗ ជាអាទិ៍នៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ ភូមិភាគឧត្តរ ព្រៃដំរីស្រុត មន្ទីរស២១ និងសង់ ព្រមទាំងនៅក្នុងសហករណ៍ត្រាំកក់"[63]

"ចំពោះទីតាំងនីមួយៗដូចបានរៀបរាប់ខាងលើ ចារីបានប្រព្រឹត្តដោយចេតនា នូវការលុកលុយរាងកាយ ជាលក្ខណៈផ្លូវភេទទៅលើជនរងគ្រោះ តាមវិធីបង្ខំដោយគ្មានការព្រមព្រៀងគ្នា ពីសំណាក់ជនរងគ្រោះដែលចារីបានដឹងច្បាស់ ហើយធាតុផ្សំជាបរិបទនៃការរំលោភផ្លូវភេទ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបំពេញ"[64]។

---

[57] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ឯកសារ **D3**, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, កថាខណ្ឌ ៥៦។

[58] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ៤៥៧ ដល់៤៥៩។

[59] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ៤៨២។

[60] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ៥០៤។

[61] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ៥៧៨។

[62] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ៧៨៥ ដល់៧៨៦។

[63] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ១៤២៦។

[64] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ១៤២៧។

53. ការវាយតម្លៃលើការចោទប្រកាន់អង្គហេតុទាំងអស់នេះ ទាក់ទងនឹងការចោទប្រកាន់ពីអត្ថិភាពនៃ "គោលនយោបាយជាផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា ពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ"[65] ធ្វើឲ្យសហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា "ទោះបីជាគោលនយោបាយនេះ មិនអាចឈានទៅដល់ការរារាំងការរំលោភផ្លូវភេទក៏ដោយ ក៏គេមិនអាចចាត់ទុកថា ការរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មមួយ ក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រើប្រាស់ ដោយបក្សកុម្មុយនីស្តកម្ពុជាក្នុងការដាក់ឲ្យអនុវត្តនូវផែនការរួមឡើយ"[66]។

54. សហមេធាវីនាំមុខសូមលើកឡើងថា ការយល់ទៅលើ "ការពិចារណា" របស់សហចៅក្រមស៊ើបអង្កេតដែលថា គោលនយោបាយផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា ពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ គឺដើម្បីរារាំងមិនឲ្យមានការកើតឡើងនូវការរំលោភផ្លូវភេទ និងដាក់ទណ្ឌកម្មចំពោះចារីនោះ មិនអាចចាត់ទុកថាជាការច្រានចោលការចោលប្រកាន់លើអង្គហេតុឡើយ។ ការពិចារណានាំមុខថា "ការរំលោភផ្លូវភេទ (មិនមែន )ជាឧក្រិដ្ឋកម្មមួយ ក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រើប្រាស់ ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ក្នុងការអនុវត្តនូវផែនការរួម" នោះ ក៏មិនអាចចាត់ទុកថាជាការច្រានចោលការចោទប្រកាន់លើអង្គហេតុបែបនេះឡើយ ជាពិសេស ដោយសារការប្រកាសនេះ ធ្វើការសន្និដ្ឋាន ដោយលើកឡើងថា "គោលនយោបាយមិនអាចរារាំងការរំលោភផ្លូវភេទឡើយ"។

55. ពាក្យពេចន៍ដែលប្រើប្រាស់នៅក្នុងកថាខណ្ឌនេះ នាំទៅដល់ការបកស្រាយដែលថា សហចៅក្រមស៊ើបអង្កេតមានទំនោរជឿជាក់ថា ការប្រព្រឹត្តិការរំលោភផ្លូវភេទ (ទោះបីថាវាបង្កើតបានជាឧក្រិដ្ឋកម្មមួយ ឬច្រើនដែរឬយ៉ាងណា នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) មិនអាចមានលទ្ធភាពទំលាក់កំហុសទៅលើសហចារីតាមរយៈទម្រង់នៃការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួមឡើយ ប្រសិនបើគោលបំណងរួម គឺជាធាតុផ្សំសំខាន់មួយក្នុងចំណោមធាតុផ្សំសំខាន់ៗដទៃទៀតនោះ។ នេះគឺគ្រាន់តែជាការយល់ឃើញមួយប៉ុណ្ណោះ។ ពាក្យបច្ចេកទេសក្នុងសេចក្តី

[65] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ១៤២៩។

[66] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤២៩។

សន្និដ្ឋានមានការប្រើប្រាស់ពាក្យ "រារាំង" និង "ដាក់ទណ្ឌកម្ម" (ប្រហាក់ប្រហែលនឹងពាក្យដែលប្រើប្រាស់សម្រាប់ការទទួលខុសត្រូវរបស់ថ្នាក់លើ) និងការចង្អុលបង្ហាញអំពីភាពមិនគ្រប់គ្រាន់នៃគោលនយោបាយ ដែលថា "គោលនយោបាយនេះមិនអាចរារាំងការរំលោភផ្លូវភេទ" អាចបញ្ជាក់ប្រាប់យ៉ាងច្បាស់។

56. សហចៅក្រមស៊ើបអង្កេតបានទុកឱ្យអង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិក្នុងការពិចារណាទៅលើសេចក្តីសន្និដ្ឋាននេះ និងមានការសន្និដ្ឋានផ្សេងមួយទៀតអំពីទម្រង់នៃការទទួលខុសត្រូវ ប្រសិនបើចាំបាច់ បន្ទាប់ពីបានត្រួតពិនិត្យទៅលើការចោទប្រកាន់លើអង្គហេតុដែលបានទទួល[67]។ ផ្នែកសម្រេចសេចក្តីរបស់ដីកាដំណោះស្រាយ បន្តឱ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យសម្រេចទៅលើការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម ដោយមិនមានការបដិសេធទៅលើការចោទប្រកាន់លើអង្គហេតុ ដោយសហចៅក្រមស៊ើបអង្កេតផ្ទាល់ ឬដោយអង្គបុរេជំនុំជម្រះ តាមសំណើរបស់ភាគី។

57. លើសពីនេះទៀត អង្គហេតុ "ទាក់ទងនឹង "បញ្ហាខុសសីលធម៌"[68] ឬទាក់ទងនឹង "អំពើខុសសីលធម៌"[69] ឬ "ក្រុមសីលធម៌បដិវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា"[70] ត្រូវបានពិភាក្សាបន្ថែមពីលើការប្រព្រឹត្តិ និងការដឹងឮរបស់ នួន ជា[71] ព្រមទាំងការប្រព្រឹត្តិ និងការដឹងឮរបស់ ខៀវ សំផន[72]។

---

[67] សូមអានសាលក្រមរបស់ឌុច កថាខណ្ឌ ៤៩៣៖ "ខណៈដែលបទបញ្ញត្តិនៅក្នុងច្បាប់របស់កម្ពុជាដែលមានលក្ខណៈស្រដៀងគ្នានេះ ពុំបានចែងអំពីការកែប្រែពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវទេនោះ អង្គជំនុំជម្រះយល់ឃើញថា ការកែប្រែប្រភេទនេះអាចធ្វើទៅបានដោយអនុលោមតាមវិធាន ៩៨(២)។"

[68] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ៩២៦។

[69] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ៩២៦។

[70] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ៩២៧។

[71] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ៩២៦ ដល់៩២៧, ៩៦៩។

[72] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ១១៨១៖ "ដូចមានរៀបរាប់នៅក្នុងផ្នែកស្តីពីអង្គហេតុ ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម គោលនយោបាយ ប.ក.ក ចំពោះអំពើអសីលធម៌ គឺត្រូវដាក់ទោសលើអ្នកដែលប្រព្រឹត្ត អំពើរំលោភសេពសន្ថវៈ។ ពុំមានភស្តុតាងក្នុងសំណុំរឿងបញ្ជាក់ថា ខៀវ សំផន បានដឹងថា អ្នកដែលប្រព្រឹត្តអំពើរំលោភសេពសន្ថវៈទាំងនោះ មិនត្រូវបានផ្តន្ទាទោសនោះឡើយ"។

58. ការ *លើកឡើង* បែបនេះមិនធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូងរួចផុតពី (១) ការកំណត់ប្រភេទឧក្រិដ្ឋកម្មនៃអំពើនៃការរំលោភផ្លូវភេទ ថាជាឧក្រិដ្ឋកម្មសំខាន់ដែលត្រូវបានចោទប្រកាន់ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (លើកលែងតែឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការរំលោភផ្លូវភេទ ជាឧក្រិដ្ឋកម្មដាច់ដោយឡែកមួយ)[73] និង (២) ការពិចារណាទៅលើភស្តុតាងទាំងអស់ដើម្បីឈានទៅដល់ការសន្និដ្ឋានថា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ទាក់ទងនឹងការរំលោភផ្លូវភេទ និង សីលធម៌ មិនមែនដើម្បី "ដាក់ទណ្ឌកម្មដល់ចារី" និង/ឬ "បង្ការឧក្រិដ្ឋកម្ម"[74]។

59. នៅពេលចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានលើកឡើងយ៉ាង ច្បាស់ថា ពួកគាត់នឹងចេញសេចក្តីសម្រេចទាក់ទងនឹង "អង្គហេតុទាំងអស់នេះ និងការកំណត់ប្រភេទនៃបទល្មើស ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា" តាមរយៈការ "បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ" ឬ "ចេញដីកាលើកលែងបទចោទ ទាក់ទងអង្គហេតុទាំងអស់នេះទាំងស្រុង ឬដោយផ្នែក"[75]។ ដីកាលើកលែងបទចោទមិនបានកើតឡើង នៅក្នុងករណីនៃការចោទប្រកាន់ពីអង្គហេតុនៃការការរំលោភផ្លូវភេទឡើយ ដូច្នេះហើយ ទើបការរំលោភផ្លូវភេទ ត្រូវបានបញ្ចូលទៅក្នុងដីកាដំណោះស្រាយ។ មេធាវីការពារក្តីមិនបានប្តឹងឧទ្ធរណ៍ចំពោះការដាក់បញ្ចូលនេះឡើយ។ ហេតុដូច្នេះ ការមិនមានដីកាលើកលែងបទចោទចំពោះបទចោទនេះ សហមេធាវីនាំមុខសូមលើកឡើងថា ការចោទប្រកាន់ពីអង្គហេតុមានអត្ថិភាព នៅក្នុងក្របខណ្ឌនៃការចោទប្រកាន់ទូលាយ ដែល

---

[73] បន្ថែមលើនេះ ដីកាដំណោះស្រាយបានស្នើនូវ ការកំណត់ប្រភេទនៃបទល្មើសជាច្រើន នៃការប្រព្រឹត្តិការរំលោភផ្លូវភេទ ជាឧក្រិដ្ឋកម្មចម្បង។ ដីកាដំណោះស្រាយក៏បានលើកឡើងផងដែរពី ទម្រង់នៃការទទួលខុសត្រូវសម្រាប់ ឧក្រិដ្ឋកម្មសំខាន់ៗទាំងអស់នេះ។ សហចៅក្រមស៊ើបអង្កេតក៏មិនបានចេញ ដីកាលើកលែងបទចោទ ដូចដែលបានតម្រូវតាមវិធាន៦៧(៣) នៃវិធានផ្ទៃក្នុង ទាក់ទងឧក្រិដ្ឋកម្មសំខាន់ៗទាំងអស់នេះ ឬទម្រង់នៃការទទួលខុសត្រូវ។ ហេតុដូច្នេះការចោទប្រកាន់លើអង្គហេតុ ដែលមានលម្អិត អំពីការប្រព្រឹត្តិការរំលោភផ្លូវភេទ នៅក្នុងទីតាំងជាក់លាក់នោះ នៅតែជាផ្នែកនៃដីកាដំណោះស្រាយ ដូច្នេះនៅតែជាសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង។

[74] ដីកាដំណោះ ស្រាយ, កថាខណ្ឌ ១៤២៩។

[75] ដូចជើងទំព័រខាងលើ, ទំព័រ ៦ (ដោយគូសបញ្ជាក់បន្ថែម)។

បង្កើតបានជាផ្នែកមួយនៃសំណុំរឿង០០២/០២ នៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខស២១ និង ក្រាំងតាចាន់[76]។

60. សហមេធាវីនាំមុខបានលើកឡើងបន្ថែមទៀតថា ការយកសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីការកំណត់ប្រភេទនៃការរំលោភផ្លូវភេទ ធ្វើបានត្រឹមតែការកំណត់ប្រភេទបទចោទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការរំលោភផ្លូវភេទ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតប៉ុណ្ណោះ។ ការធ្វើបែបនេះមិនកំណត់ទៅលើវិសាលភាពនៃការចោទប្រកាន់លើអង្គហេតុនៅក្នុងសំណុំរឿង០០២/០២ ឬ លទ្ធភាពនៃការកំណត់ប្រភេទនៅក្នុងសាលក្រមនៃអង្គហេតុទាំងនោះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត និង/ឬ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត។

61. ប្រហែលគ្នានេះដែរ សហព្រះរាជអាជ្ញាបានស្នើសុំការបញ្ជាក់បំភ្លឺ ហើយសហមេធាវីនាំមុខក៏បានឆ្លើយតបចំពោះសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺនេះ បានផ្តោតសំខាន់លើការពិភាក្សាអំពីការប្រព្រឹត្តិការរំលោភផ្លូវភេទ ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការរំលោភផ្លូវភេទ ជាឧក្រិដ្ឋកម្មដាច់ដោយឡែកមួយក្នុងឆ្នាំ ១៩៧៥។ សហមេធាវីនាំមុខយល់ស្របថា ចម្លើយតបរបស់សហមេធាវីនាំមុខចំពោះសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺនេះ មានការពិភាក្សាអំពីភស្តុតាងដែលស្ថិតក្រៅបរិបទនៃការរៀបការដោយបង្ខំ[77] ដែលមានការសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតមិនបាន "បញ្ជូនជនជាប់ចោទទៅជំនុំជម្រះ ពីបទរំលោភផ្លូវភេទដែលស្ថិតក្រៅបរិបទនៃការរៀបការដោយបង្ខំឡើយ"[78]។ ប៉ុន្តែ ចម្លើយតបនេះ និងការសម្រេចសេចក្តី សម្រាប់តែការពិចារណាទៅលើការរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្ស

[76] បញ្ជីនៃកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយ ទាក់ទងសំណុំរឿង ០០២/០២, ឯកសារ **E301/9/1.1**, ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤។ ទំព័រ ៤។

[77] ចម្លើយតបរបស់ សហមេធាវីនាំមុខ ចំពោះសំណើសុំការបញ្ជាក់បំភ្លឺ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣២ ដល់៤១។

[78] ចម្លើយតបរបស់ សហមេធាវីនាំមុខ ចំពោះសំណើសុំការបញ្ជាក់បំភ្លឺ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤០។

ជាតិផ្ទាល់ខ្លួនប៉ុណ្ណោះ ហើយមិនបានជំទាស់ថា ការចោទប្រកាន់ពីអង្គហេតុនៃការប្រព្រឹត្តិការរំលោភផ្លូវភេទ មិនត្រូវបានរួមបញ្ចូលនៅក្នុងដីកាដំណោះស្រាយឡើយ[79]។

62. អនុស្សរណៈស្តីពីអញ្ញត្រកម្មដោះស្រាយទៅលើទឡ្ហីករណ៍របស់ភាគីស្តីពីការកំណត់ប្រភេទនៃបទល្មើស ដោយមិនបានសម្រេចទៅលើ *ការយោង* របស់អង្គជំនុំជម្រះសាលាដំបូង។ ចាប់ពីពេលនោះមក អនុស្សរណៈនេះបានក្លាយជាមូលដ្ឋាននៃសេចក្តីសម្រេចលើការសួរដេញដោល[80] ព្រមទាំងមូលដ្ឋាននៃដីកាសម្រេចដែលរងការជំទាស់[81]។

**(២) <u>ហេតុអ្វីទើបដីកាសម្រេចដែលរងការជំទាស់ បង្កើតបានជាការបញ្ចប់កិច្ចដំណើរការនីតិវិធី</u>**

63. ដីកាសម្រេចដែលរងការជំទាស់បញ្ជាក់ថា៖

"ផ្អែកលើការសម្រេចទាំងអស់នេះ ឧក្រិដ្ឋកម្មនៃការរំលោភផ្លូវភេទ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ នៅក្នុងផ្នែកសម្រេចសេចក្តី នៃដីកាដំណោះស្រាយ ត្រូវបកស្រាយថាមិនរួមបញ្ចូលនូវការរំលោភផ្លូវភេទដែលបានប្រព្រឹត្តិ នៅក្នុងមន្ទីរសន្តិសុខនិងសហករណ៍ ដែលស្ថិតក្រៅបរិបទនៃការរៀបការដោយបង្ខំ។ មិនមានឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ដទៃទៀត ពឹងផ្អែកទៅលើមូលដ្ឋាននៃអង្គហេតុ នៃការរំលោភផ្លូវភេទស្ថិតក្រៅការរៀបការដោយបង្ខំឡើយ។ ការបកស្រាយនេះត្រូវបានគាំទ្របន្ថែមទៀត ដោយទម្រង់នៃការទទួលខុសត្រូវ ដែលមាននៅក្នុងដីកាដំណោះស្រាយ ដែលពិចារណាតែការរំលោភផ្លូវភេទ នៅក្នុងបរិបទនៃការរៀបការដោយបង្ខំ"[82]។

64. ការបកស្រាយដីកាសម្រេចដែលរងការជំទាស់ដោយភាគីនានា នាំឱ្យមានការយល់ឃើញ ដែលអាចខុស ឬយ៉ាងណាទៀតនោះ ថា នេះគឺជាការចោទប្រកាន់អង្គហេតុ ដែលមិនបង្កើតបានជាផ្នែកមួយនៃបណ្តឹងមកកាន់អង្គជំនុំជម្រះសាលាដំបូងឡើយ[83]។

---

[79] ចម្លើយតបរបស់ សហមេធាវីនាំមុខ ចំពោះសំណើសុំការបញ្ជាក់បំភ្លឺ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤៥។

[80] សេចក្តីសម្រេចលើការសួរដេញដោល, កថាខណ្ឌ ១១។

[81] ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២៣។

[82] ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៥។

[83] ការនេះបានសន្មតថា (១) ដីកាលើកលែងបទចោទត្រូវចេញដោយច្បាស់លាស់ ទាក់ទងការចោទប្រកាន់ពីអង្គហេតុទាំងអស់ដែលចោទជាបញ្ហា ឬ(២) ដីកាលើកលែងបទចោទត្រូវចេញដោយប្រយោល ឬ(៣) ដីកាលើកលែងបទចោទមិនត្រូវបានចេញ

65. សហមេធាវីនាំមុខសូមលើកឡើងថា ដីកាសម្រេចដែលរងការជំទាស់ មិនបានបញ្ជាក់ ឬមិនបានលើកសំអាងហេតុថា មានដីកាលើកលែងបទចោទទាក់ទងបទចោទ ដោយផ្ទាល់ឬដោយប្រយោលទេ។ ទោះបីជាដីកាសម្រេចបន្តគាំទ្រដល់ឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការកំណត់ប្រភេទសារជាថ្មី ចំពោះការចោទប្រកាន់ទៅលើអង្គហេតុ តែដីកាសម្រេចមិនបានគាំទ្រឬច្រានចោល សារណារបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ដីកាបានសម្រេចទៅលើការកំណត់ប្រភេទជាថ្មី នៃការចោទប្រកាន់អង្គហេតុទាំងអស់នោះ ថាជាឧក្រិដ្ឋកម្មមួយនៃឧក្រិដ្ឋកម្មសំខាន់ៗ តាមរយៈទម្រង់នៃការទទួលខុសត្រូវមួយ ជាសំណើដែលមិនត្រូវបានធ្វើឡើង ឬមិនត្រូវបានឆ្លើយតប នៅក្នុងសំណើសុំការបញ្ជាក់គាំទ្រ។

66. ការនេះនាំទៅដល់សេណារីយ៉ូមួយ ដែលអង្គជំនុំជម្រះសាលាដំបូង ពិចារណាថាខ្លួនមានសេរីភាពក្នុងការពិចារណា អំពីការប្រព្រឹត្តិការរំលោភផ្លូវភេទ នៅពេលសម្រេចទៅលើ "ស្ថានភាពនៅក្នុងមន្ទីរសន្តិសុខទាំងនោះ" ប៉ុន្តែមិនមែននៅពេលដែលវាអាចបង្កើត បានជាឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់មួយ ក្នុងចំណោមឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ជាច្រើន ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទារុណកម្ម អំពើអមនុស្សធម៌ដទៃទៀត តាមរយៈការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់មនុស្ស ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ដទៃទៀត "ផ្អែកលើមូលដ្ឋាននៃទម្រង់នៃការទទួលខុសត្រូវដទៃទៀត"[84]។

### (ខ) សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការដាក់បណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ

67. សហមេធាវីនាំមុខបានលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការដាក់ បណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះពីព្រោះ សិទ្ធិនេះត្រូវបានសម្រេចនាពេលកន្លងមកថា "អព្យាក្រិត" ហើយត្រូវបានអនុញ្ញាតដល់ "ភាគីណាមួយដែលមានផលប្រយោជន៍ផ្លូវច្បាប់ ក្នុងការប្តឹងឧទ្ធរណ៍សេចក្តីសម្រេច

---

ហើយអង្គជំនុំជម្រះសាលាដំបូង បានបញ្ចប់កិច្ចដំណើរការនីតិវិធី ប្រឆាំងការចោទប្រកាន់លើអង្គហេតុបែបនេះ ហើយនឹងបទចោទជាលទ្ធផលទាំងអស់។

[84] ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៨។

របស់អង្គជំនុំជម្រះសាលាដំបូង ដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី"[85]។ សហមេធាវីនាំមុខទទួចថា ការប្រើប្រាស់សិទ្ធិនេះមិនកំណត់សម្រាប់ភាគីណាមួយឡើយ ហើយសិទ្ធិនេះមិនត្រូវបានកម្រិតកំណត់ច្បាស់លាស់ ដោយបទប្បញ្ញត្តិនៅក្នុងវិធានផ្ទៃក្នុងឡើយ[86]។

68. សហមេធាវីនាំមុខលើកឡើងថា ការបញ្ចប់កិច្ចដំណើរការនីតិវិធី ទាក់ទងការចោទប្រកាន់លើអង្គហេតុពាក់ព័ន្ធ ពិតជានឹងនាំទៅដល់ការមិនអាចសម្រេចបាន ចំពោះពិរុទ្ធភាពរបស់សហជនជាប់ចោទ ទាក់ទងឧក្រិដ្ឋកម្មសំខាន់ៗ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ សហមេធាវីនាំមុខលើកឡើងថា ការមិនអាចសម្រេចបាន នូវពិរុទ្ធភាពរបស់សហជនជាប់ចោទនេះ នឹងមិនអាចកែប្រែបានដោយការប្ដឹងសាទុក្ខឡើយ នៅពេលដែលចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយសារតែមិនមានទាំងការផ្ដន្ទាទោស ឬការលើកលែងបទចោទ សម្រាប់បទចោទទាំងអស់នេះ។ សហមេធាវីនាំមុខយល់ស្របថា ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានសិទ្ធិជាស្វ័យប្រវត្តិក្នុងការប្ដឹងឧទ្ធរណ៍ក្នុងករណីនេះឡើយ វាអាស្រ័យទៅលើសេចក្ដីសម្រេច របស់សហព្រះរាជអាជ្ញា ក្នុងការដាក់បណ្ដឹងឧទ្ធរណ៍[87]។ ប៉ុន្តែនៅក្នុងករណីបច្ចុប្បន្ន សូម្បីតែសិទ្ធិយថាហេតុនេះ ក៏មិនត្រូវបានបង្កើតឡើងនោះឡើយ[88]។

69. ជាលទ្ធផលដូចដែលបានលើកឡើងពីខាងលើ ដោយសារតែមិនមានការផ្ដន្ទាទោស ឬការលើកលែងបទចោទចំពោះចំណុចនេះ ដើមបណ្ដឹងរដ្ឋប្បវេណីនឹងមិនមានលទ្ធភាព ឲ្យមានការទទួលស្គាល់ពីអង្គជំនុំជម្រះសាលាដំបូង នូវព្យសនកម្មដែលទទួលរង "ជាលទ្ធផលនៃការប្រព្រឹត្តិ

---

[85] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្ដីពី ទំនាក់ទំនងជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ឯកសារ **E95/8/1/4**, ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២, កថាខណ្ឌ ៩។

[86] សូមមើលសេចក្ដីសម្រេចលើសំណើ របស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងបណ្ដឹងសាទុក្ខ ក្នុងសំណុំរឿង០០២/០១, ឯកសារ **F10/2**, ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤, កថាខណ្ឌ ១២។

[87] *សូមមើល* វិធាន ១០៥(១)(គ) នៃវិធានផ្ទៃក្នុង។

[88] ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើសេចក្ដីសម្រេចលើ សំណើសុំការបញ្ជាក់បំភ្លឺ ត្រូវបានអនុញ្ញាត នោះសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដី នឹងបន្តរក្សាសិទ្ធិរបស់ខ្លួនក្នុងការប្ដឹងសាទុក្ខ ទៅលើការសម្រេចលើអង្គហេតុ និងអង្គច្បាប់ ទាក់ទងការប្រព្រឹត្តការរំលោភផ្លូវភេទ នៅដំណាក់កាលចេញសាលក្រម។

ឧក្រិដ្ឋកម្ម" ដែលសហជនជាប់ចោទអាចត្រូវបានផ្តន្ទាទោស។ នេះគឺជាគោលបំណងជាសារវន្ត នៃសំណងផ្លូវចិត្ត និងសមូហភាព ដែលដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនទទួលបាន ដោយសារតែមានកំហុសអង្គច្បាប់ ដូចបានចោទប្រកាន់ខាងក្រោម។

70. បន្ថែមលើនេះសហមេធាវីនាំមុខសូមលើកឡើងថា នៅដំណាក់កាលសាលក្រម ការផ្តល់ជូនតាមការទាមទារសំណងរដ្ឋប្បវេណី អាចត្រូវបានផ្តល់ជូនតែចំពោះព្យសនកម្ម ដែលទទួលរង "ជាលទ្ធផលនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលជនជាប់ចោទត្រូវបានផ្តន្ទាទោសតែប៉ុណ្ណោះ"[89]។

71. លើសពីនេះសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះសំណង នៅដំណាក់កាលសាលក្រម ចំពោះចំណុចជាក់លាក់នេះ សិទ្ធិដែលមានស្វយ័តភាព[90] នឹងមិនបង្កើនចំពោះដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ហេតុដូច្នេះ ប្រសិនបើបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន ត្រូវបានសម្រេចថាមិនអាចទទួលយកបាន ការសម្រេចនេះនឹងរឹតបន្តឹងលទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការប្តឹងសាទុក្ខបណ្តឹងរដ្ឋប្បវេណី ដែលមាននៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលឆ្លើយតបចំពោះព្យសនកម្មជាក់លាក់ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ដោយសារការរំលោភផ្លូវភេទ ដែលស្ថិតក្រៅបរិបទនៃការរៀបការដោយបង្ខំ។

72. ជាលទ្ធផល សហមេធាវីនាំមុខសូមលើកឡើងថា ការប្រើប្រាស់សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍បន្ទាន់បង្ខំគឺជាភាពចាំបាច់នៅក្នុងករណីបច្ចុប្បន្ន ដើម្បីផលប្រយោជន៍របស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីរួម។

## VI. **អង្គសេចក្តី**

**(ក) មូលដ្ឋាន ១**

[89] វិធាន ២៣ស្ទួនពីរ(១)(ក) នៃវិធានផ្ទៃក្នុង។

[90] វិធាន ១០៥(១)(គ)នៃវិធានផ្ទៃក្នុង។

73. សហមេធាវីនាំមុខលើកឡើងថាកង្វះយោបល់ដែលមានសំអាងហេតុអំពីចំណោទជាក់ស្តែងនៃ saisine រារាំងមិនឱ្យដើមបណ្តឹងរដ្ឋប្បវេណីយល់ដឹងអំពីមូលដ្ឋាននៃសេចក្តីសម្រេចនេះ។ សហមេធាវីនាំមុខលើកឡើងថាកង្វះយោបល់ដែលមានសំអាងហេតុនេះ និងការសម្រេចលើបញ្ហា hors sujet បណ្តាលឱ្យមានកំហុសជាក់ស្តែងក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលប៉ះពាល់ប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។

74. សហមេធាវីនាំមុខលើកឡើងថាសេចក្តីសម្រេចដែលរងការជំទាស់គឺផ្អែកលើការយល់ច្រឡំជាសារវ័ន្តអំពីលក្ខណៈនៃសំណើសុំការបញ្ជាក់បំភ្លឺ។ សំណើសុំការបញ្ជាក់បំភ្លឺបានទទូចឱ្យអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់អះអាងអំពីការចោទប្រកាន់លើអង្គហេតុអំពីបទរំលោភផ្លូវភេទក្នុងសំណុំរឿង ០០២/០២ ទៅនឹងអង្គហេតុនានាទាក់ទងនឹងការរំលោភផ្លូវភេទនៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខ ស២១។

75. អង្គជំនុំជម្រះសាលាដំបូងបានយល់ច្រឡំអំពីសំណើនេះ និងបានចេញសេចក្តីសម្រេចស្តីពីការកំណត់បទចោទចំពោះការចោទប្រកាន់លើអង្គហេតុអំពីបទរំលោភផ្លូវភេទជំនួសវិញ[91]។ សហមេធាវីនាំមុខ ពុំបានស្នើសុំឱ្យធ្វើការកំណត់បទចោទឡើងវិញឡើយ ប៉ុន្តែសុំការឯកភាព (ឬមិនឯកភាព) អំពីការចោទប្រកាន់លើអង្គហេតុទាំងនោះ។ សេចក្តីសម្រេចដែលរងការជំទាស់ផ្អែកមូលដ្ឋានលើអនុស្សរណៈស្តីពីអញ្ញត្រកម្ម ដែលកង្វះទម្រង់ការនៃអញ្ញត្រកម្មនេះបន្តជាផ្នែកមួយនៃសេចក្តីសម្រេចដែលរងការជំទាស់។ វាបង្កើតភាពស្រពិចស្រពិលក្នុងកម្រិតមួយ ដែលមាន

[91] សំណើសុំការបញ្ជាក់បំភ្លឺ, កថាខណ្ឌ ២៧៖ "តាមរយៈសារណានេះ សហមេធាវីនាំមុខស្នើសុំការបញ្ជាក់បំភ្លឺពីអង្គជំនុំជម្រះសាលាដំបូងដែលថាខ្លួនត្រូវបានប្តឹង និងនៅតែត្រូវបានប្តឹងអំពីអង្គហេតុនៃការរំលោភផ្លូវភេទ និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់យ៉ាងត្រឹមត្រូវក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ បើទោះមិនមែនជាឧក្រិដ្ឋកម្មដាច់ដោយឡែកនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាការរំលោភផ្លូវភេទ" ប្រៀបធៀបជាមួយសេចក្តីសម្រេចដែលរងការជំទាស់, ទំព័រ ៨៖ "បដិសេធសំណើសុំការកំណត់បទចោទឡើងវិញចំពោះ ការចោទប្រកាន់លើអង្គហេតុអំពីការរំលោភផ្លូវភេទនៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ និងស២១"។

តម្លៃស្មើទៅនឹងកំហុសជាក់ស្ដែងក្នុងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានធ្វើឲ្យខូចប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី[92]។

76. ល្គឹកណាសេចក្ដីសម្រេចដែលរងការជំទាស់ទុកបញ្ហានៃ saisine ឲ្យនៅស្ងៀមស្ងាត់ សហមេធាវីនាំមុខអាចត្រឹមតែផ្ដល់យោបល់ទាក់ទងមូលដ្ឋាននៃសេចក្ដីសម្រេចនេះប៉ុណ្ណោះ។ និយាយសាមញ្ញ saisine មានមុនការកំណត់បទចោទ។ អង្គជំនុំជម្រះសាលាដំបូងពុំមានសិទ្ធិដើម្បី កំណត់បទចោទឡើងវិញអំពីការចោទប្រកាន់លើអង្គហេតុដែលខ្លួនពុំត្រូវបានប្ដឹងឲ្យពិនិត្យ និងចាត់ការត្រឹមត្រូវជាមុននោះទេ។

77. ហេតុដូច្នេះ សហមេធាវីនាំមុខលើកឡើងថាសេចក្ដីសម្រេចដែលរងការជំទាស់ ពុំអាចត្រូវបានផ្ដល់សំអាងហេតុ ឬបកស្រាយដើម្បីដកចេញការពិចារណាអំពីភស្ដុតាងស្ដីពីការរំលោភផ្លូវភេទពីសំណាក់អង្គជំនុំជម្រះសាលាដំបូងបានឡើយ ដោយហេតុថាសេចក្ដីសម្រេចនេះកើតចេញពីផ្នែកដែលខ្លួនចង់ដកចេញ។

78. សហមេធាវីនាំមុខលើកឡើងថាទោះជាអង្គជំនុំជម្រះសាលាដំបូងពេញចិត្តការកំណត់បទចោទមួយជាងមួយទៀតក៏ដោយ ក៏វាជាការសម្រេចមួយដែលពឹងផ្អែកលើការពិចារណាអំពីភស្ដុតាង និងការវាយតម្លៃរបស់ខ្លួនអំពីធាតុផ្សំនៃបទល្មើសនៅដំណាក់កាលពិភាក្សាសម្រេច[93]។ ក្នុងបរិបទ អ.វ.ត.ក ខ្លួនអាច ឬអាច មិន ពឹងផ្អែកលើវិធីនៃការស្នើសុំភស្ដុតាងដោយភាគី។ អង្គជំនុំជម្រះសាលាដំបូងនៅមានឆន្ទានុសិទ្ធិដើម្បីកំណត់ប្រភេទនៃភស្ដុតាងតាមមធ្យោបាយដែលខ្លួនយល់ថាសម

---

[92] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១,ឯកសារ E163/5/1/13, កថាខណ្ឌ ៣០។

[93] វិធានផ្ទៃក្នុង ៩៨។ សូមអានសាលក្រម ឌុច កថាខណ្ឌ ៤៩៦៖ " ដូច្នេះអង្គជំនុំជម្រះយល់ឃើញថា វិធាន ៩៨(២) នៃវិធានផ្ទៃក្នុងអាចអនុញ្ញាតឲ្យអង្គជំនុំជម្រះផ្លាស់ប្ដូរការកំណត់បទចោទដែលមានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ដើម្បីឲ្យស្របជាមួយនឹងទម្រង់នៃការទទួលខុសត្រូវថ្មីមួយ ប្រសិនបើមានការផ្លាស់ប្ដូរការកំណត់បទចោទ។ នៅពេលមានការផ្លាស់ប្ដូរការកំណត់បទចោទ អង្គជំនុំជម្រះត្រូវតែធានាផងដែរថា (១) មិនមានការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និង (២) ទម្រង់នៃការទទួលខុសត្រូវថ្មីនេះអាចយកមកអនុវត្តបាននៅ អ.វ.ត.ក.។

ស្របចំពោះការសម្រេចអំពីបទល្មើសដែលត្រូវបានចោទប្រកាន់ ដរាបណាពុំមានធាតុផ្សំថ្មីត្រូវបានដាក់បន្ថែម។ ប៉ុន្តែ saisine in rem នៃការចោទប្រកាន់លើអង្គហេតុ ហូរដោយស្វយប្រវត្តិពីការបញ្ជូនដីកាដំណោះស្រាយទៅអង្គជំនុំជម្រះសាលាដំបូង។ នៅដំណាក់កាលជំនុំជម្រះអង្គជំនុំជម្រះសាលាដំបូងអាចត្រឹមតែផ្តន្ទាទោស ឬលើកលែងការចោទប្រកាន់លើជនជាប់ចោទចំពោះ ការចោទប្រកាន់បែបនេះ។ អង្គជំនុំជម្រះពុំមានសិទ្ធិដើម្បីយករួចខ្លួនពីបញ្ហាទាំងនេះ មុនពេលកំណត់ឡើយ។

79. សហមេធាវីនាំមុខទទួលស្គាល់ថា ក្នុងសំណុំរឿងព្រហ្មទណ្ឌជាតិ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាពីពេលមុនថាខ្លួន "ត្រូវបានប្តឹងដោយមិនត្រឹមត្រូវ" អំពី "បទល្មើស" ជាក់លាក់មួយចំនួន និងបានដកបទល្មើសទាំងនោះពីវិសាលភាពនៃការជំនុំជម្រះ[94]។ ក្នុងសំណុំរឿងនោះ បទល្មើសដែលត្រូវបានចោទប្រកាន់ ពុំត្រូវបានចោទដោយត្រឹមត្រូវចំពោះ "ព្យសនកម្មដ៏ជាក់លាក់ចំពោះមេធាវីការពារក្តីជនជាប់ចោទ"[95]។ ក្នុងសំណុំរឿងបច្ចុប្បន្ន ដូចដែលបានបង្ហាញក្នុងប្រវត្តិនីតិវិធី ការចោទប្រកាន់នានាអំពីការរំលោភផ្លូវភេទ និងអង្គហេតុសំខាន់ៗត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង002 តាំងតែពីឆ្នាំ ២០០៩[96]។

80. សហមេធាវីនាំមុខក៏ទទួលស្គាល់ថាអង្គបុរេជំនុំជម្រះបានដកឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាបទល្មើសរំលោភផ្លូវភេទ ជាបទល្មើសដាច់ដោយឡែកមួយពីយុត្តាធិការពេលវេលានៃ អ.វ.ត.ក។ ពួកគាត់ទទួលស្គាល់ទៀតថាសហចៅក្រមស៊ើបអង្កេតពុំបានផ្តល់ទស្សនៈ និងការពិចារណារបស់ខ្លួនស្តីពីការរំលោភផ្លូវភេទ ដែលត្រូវបានប្រើប្រាស់ជាបញ្ហាមួយនៃគោលនយោបាយដើម្បីជំរុញគោលបំណងរួម។

81. ប៉ុន្តែសហមេធាវីនាំមុខលើកឡើងថាការវាយតម្លៃស្ថាពរអំពីថាតើភស្តុតាងដែលត្រូវបានស្តាប់ស្តីពីការរំលោភផ្លូវភេទនៅតាមទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់

---

[94] សេចក្តីសម្រេចលើអញ្ញត្រកម្ម នានារបស់មេធាវីការពារក្តី, ឯកសារ E122, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១,កថាខណ្ឌ ២២។

[95] *ដូចឯកសារយោងខាងលើ*។

[96] កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ, ឯកសារ D275, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩, កថាខណ្ឌ ១១។ កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ, ឯកសារ E3/576, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩, កថាខណ្ឌ ១០។

អំពើអមនុស្សធម៌ដទៃទៀត តាមរយៈការរំលោភផ្លូវភេទ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាការធ្វើទារុណកម្ម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់អំពើអមនុស្សធម៌ដទៃទៀត តាមរយៈការប៉ះពាល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ គឺជាការសម្រេចមួយសម្រាប់ដំណាក់កាលស្តាពរនៃសាលក្រមនៅពេលដែលភស្តុតាងទាំងអស់ស្ថិតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

**(ខ) មូលដ្ឋាន II**

82. សហមេធាវីនាំមុខលើកឡើងថាទោះជាកង្វះសំអាងហេតុក្នុងសេចក្តីសម្រេចដែលរងការជំទាស់ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំអាចបានឈានដល់ការសន្និដ្ឋានដូច្នោះឡើយ ប្រសិនបើពួកគាត់បានអនុវត្តច្បាប់ដោយត្រឹមត្រូវ។ ហេតុដូច្នេះ សហមេធាវីនាំមុខសូមចោទថាអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តិកំហុសអង្គច្បាប់ដែលធ្វើឲ្យសេចក្តីសម្រេចនេះអស់សុពលភាព។

83. សហមេធាវីនាំមុខលើកឡើងថាការចោទប្រកាន់លើអង្គហេតុពីបទរំលោភផ្លូវភេទ នៅតែត្រូវបានដាក់បញ្ចូលក្នុងខ្លឹមសារនៃដីកាដំណោះស្រាយដោយគ្មានការដកចេញជាក់លាក់នូវ ការចោទប្រកាន់លើអង្គហេតុ និង/ឬ ឧក្រិដ្ឋកម្មសំខាន់ៗដែលទាក់ទង។

84. សហមេធាវីនាំមុខលើកឡើងថាដីកាសម្រេចលើកលែងការចោទប្រកាន់ដ៏ជាក់លាក់ នឹងអាចធ្វើឲ្យសហព្រះរាជអាជ្ញា (និងដើមបណ្តឹងរដ្ឋប្បវេណី) មានសិទ្ធិប្តឹងឧទ្ធរណ៍ជំទាស់ដីកាលើកលែងការចោទប្រកាន់នេះ។ ការបដិសេធការចោទប្រកាន់ដ៏ជាក់លាក់នេះ នឹងអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា និង *ជាលទ្ធផល* ដើមបណ្តឹងរដ្ឋប្បវេណីយល់អំពីសំអាងហេតុដែលជាមូលដ្ឋាន និងកំណត់មូលដ្ឋាន និងវិសាលភាព នៃបណ្តឹងឧទ្ធរណ៍របស់ពួកគាត់។ ចំណុចនេះពុំបានកើតមានក្នុងសំណុំរឿងបច្ចុប្បន្នឡើយ។

85. សហមេធាវីនាំមុខលើកឡើងថានៅដំណាក់កាលនោះ ភាគីដែល *បាន* មានសិទ្ធិប្តឹងឧទ្ធរណ៍គឺមេធាវីការពារក្តី[97] ដែលអាចបានផ្តល់សំអាងហេតុ និងប្តឹងឧទ្ធរណ៍ដើម្បីដកការចោទប្រកាន់លើអង្គហេតុពាក់ព័ន្ធ ពីដីកាដំណោះស្រាយ។ នេះជាការពិត ដោយហេតុថាការរំលោភផ្លូវភេទក្រៅបរិបទ

---

[97] *សូមមើល* វិធានផ្ទៃក្នុង៧៤(៣),៧៦។

នៃអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានជំទាស់នៅដំណាក់កាលស៊ើបសួរ។ ប៉ុន្តែគ្មានក្រុមមេធាវីការពារក្តីណាមួយបានប្រើប្រាស់មធ្យោបាយនេះឡើយ។

86. ក្រុមមេធាវីការពារក្តីពុំបានជំទាស់ការដាក់បញ្ចូលនូវកថាខណ្ឌនានាដែលមានការចោទប្រកាន់លើអង្គហេតុ ដូចដែលពួកគាត់បានធ្វើជាមួយឧក្រិដ្ឋកម្មនៃការនិរទេសដែលត្រូវបានចោទឡើយ[98]។ ជាការពិត សារណាទាំងពីររបស់មេធាវីការពារក្តី ខៀវ សំផន E99/3 និង E348 ធ្វើឡើងដោយផ្អែកលើមូលដ្ឋានថាដីកាដំណោះស្រាយត្រូវបានប្តឹងឲ្យពិនិត្យនិងចាត់ការចំពោះការចោទប្រកាន់លើអង្គហេតុអំពីការរំលោភផ្លូវភេទ[99]។

87. ខុសពីការចោទប្រកាន់ក្នុងច្បាប់ខម៊ែរឡ ដែលជាផលិតផលនៃឆន្ទានុសិទ្ធិរបស់អយ្យការ ដីកាដំណោះស្រាយក្នុងបរិបទច្បាប់ស៊ីវិលឡ អ.វ.ត.ក គឺកើតចេញពីគោលការណ៍នៃភាពតឹងរ៉ឹងចំពោះច្បាប់[100] ។ ហេតុដូច្នេះ ដីកាលើកលែងចោទប្រកាន់ដ៏ជាក់លាក់អំពីការចោទប្រកាន់លើអង្គហេតុគឺជាការចាំបាច់[101]។

---

[98] *សេចក្តីសន្និដ្ឋានមេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីអញ្ញត្រកម្មដែលអង្គជំនុំជម្រះមិនទាន់បានដោះស្រាយ,* ឯកសារ E306/2, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤។

[99] *សំណើសុំឲ្យមានការតទល់គ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ជាមួយនឹងសាក្សី ស្រី ផន និងដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង និងស្នើសុំឯកសារថតសំឡេងនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សយ សែន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត,* ឯកសារ E348, ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥, កថាខណ្ឌ ៦-១០។ ចម្លើយទៅនឹងការស្នើសុំរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងការកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ, ឯកសារ E99/3, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, កថាខណ្ឌ ១៤៖ "អង្គបុរេជំនុំជម្រះពុំបានធ្វើវិសោធនកម្មការកំណត់បទចោទអំពីអង្គហេតុទាំងនោះ៖ នៅពេលលុបចោលវាក្យខណ្ឌស្តីពីការរំលោភសេពសន្ថវៈ ពីក្នុងកថាខណ្ឌទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គបុរេជំនុំជម្រះបានកែប្រែវិសាលភាពនៃច្បាប់អនុវត្ត"។

[100] សាលដីកាលើបណ្តឹងឧទ្ធរណ៍ភ្លាមៗជំទាស់ដីការបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ, ឯកសារ E318/1/10/1/5/7, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២, កថាខណ្ឌ ៣៧៖ "ជាទូទៅ យុត្តាធិការច្បាប់ស៊ីវិលឡភាគច្រើនបានអនុវត្តគោលការណ៍ភាពតឹងរ៉ឹងចំពោះច្បាប់ (ឬការចោទប្រកាន់ជាចាំបាច់) ដែលអនុលោមតាមនេះ អយ្យការគ្មានឆន្ទានុសិទ្ធិដើម្បីបញ្ឈប់ ឬស្នើសុំការបញ្ឈប់បណ្តឹងអាជ្ញានៅពេលដែលវាត្រូវបានផ្តួចផ្តើម ហើយតុលាការដែលមានសិទ្ធិអំណាចដើម្បីបញ្ចប់កិច្ចដំណើរការនីតិវិធី អាចធ្វើដូច្នោះបានតាមសំអាងហេតុដែលបញ្ជាក់ច្បាស់ក្នុងច្បាប់។ ភាពអាចអនុវត្តបាននៃគោលការណ៍ភាពតឹងរ៉ឹងចំពោះច្បាប់ ក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ អាចមានភាពមិនចុះសម្រុងពិសេសទាក់ទងនឹងការសម្រេចថាតើត្រូវចោទប្រកាន់ ឬយ៉ាងណា។ លើសពីនេះ សូម្បីនៅក្នុងទ្វីបអឺរ៉ុប មានការសាបរលាប *បណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះសំណើសុំការបញ្ជាក់ពីវិសាលភាពទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

88. ទាក់ទងនឹងដីកាលើកលែងចោទប្រកាន់ implicit ដែលមិនមានភាពជាក់លាក់[102] សហមេធាវីនាំមុខបានលើកឡើងពីពេលមុនថាការលើកលែងការចោទប្រកាន់គួរមានភាពជាក់លាក់[103]។ បញ្ហានៃដីកាលើកលែងការចោទប្រកាន់ដ៏ជាក់លាក់ពុំត្រូវបានពិភាក្សាក្នុងសេចក្តីសម្រេច ដែលរងការជំទាស់។ ការឆ្លើយតបរបស់សហមេធាវីនាំមុខលើបញ្ហានេះក៏ពុំត្រូវបានពិចារណាផងដែរ[104]។

89. សហមេធាវីនាំមុខបន្ថែមថាអង្គជំនុំជម្រះសាលាដំបូងក៏មានឆន្ទានុសិទ្ធិដើម្បីមិនឯកភាពជាមួយការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេត មិនថាវាទាក់ទងសេចក្តីសន្និដ្ឋានអំពីធាតុផ្សំនៃបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវឡើយ ល្គឹកណាគ្មានការបន្ថែមធាតុផ្សំថ្មី[105]។

90. សហមេធាវីនាំមុខលើកឡើងថាការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងការរំលោភផ្លូវភេទ និងគោលនយោបាយ ពុំចងកាតព្វកិច្ចចំពោះអង្គជំនុំជម្រះសាលាដំបូងឡើយ។ ក្រោយពេលពិចារណាអំពីភស្តុតាងនេះ អង្គជំនុំជម្រះសាលាដំបូងអាចធ្វើសេចក្តីសន្និដ្ឋានមួយខុសពីនេះអំពីអត្ថិភាពនៃភស្តុតាង (ឬផ្សេងពីនេះ) ទាក់ទងនឹងការរំលោភផ្លូវភេទក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ សេចក្តីសម្រេចដែលរងការជំទាស់ពុំត្រឹមតែមានអានុភាពដកឆន្ទានុសិទ្ធិនោះពីអង្គជំនុំជម្រះសាលាដំបូងដោយគ្មានសំអាងហេតុគ្រប់គ្រាន់ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងផ្អែកលើការអនុវត្តមិនត្រឹមត្រូវនូវច្បាប់។

---

បន្តិចម្តងៗ តាមរយៈការបង្ហាញអំពីលិខិតុបករណ៍ផ្សេងពីនេះ។ ប៉ុន្តែការនិយាយអំពីគោលការណ៍នេះអាចត្រូវបានប្រទះឃើញក្នុងដំណាក់កាលជំនុំជម្រះ *ក្នុងចំណោមប្រការផ្សេងៗ* តាមមធ្យោបាយដែលប្រព័ន្ធច្បាប់ស៊ីវិលឡូ ដោះស្រាយឧបសគ្គចំពោះការបន្តកិច្ចដំណើរការនីតិវិធី ដូចជាការមិនមានសម្បទាគ្រប់គ្រាន់ដើម្បីទទួលបានការជំនុំជម្រះ"។

[101] ប្រៀបធៀបដីកាដំណោះស្រាយ កថាខណ្ឌ ១៤២៩ ជាមួយដីកាលើកលែងការចោទប្រកាន់ HISENE HABRE Hissein Habre *et al.*, *Ordonnance de non-lieu partiel, de mise en accusation et de renvoi devant la chambre africaine extraordinaire d'assises*, 13 February 2015, p. 185.

[102] ចម្លើយតបរបស់ ខៀវ សំផន ស្តីពីការបញ្ជាក់អះអាង, កថាខណ្ឌ ១២។

[103] ការឆ្លើយតបស្តីពីការបញ្ជាក់អះអាងអំពីវិសាលភាព, កថាខណ្ឌ ៣។

[104] សេចក្តីសម្រេចដែលរងការជំទាស់យោងទៅរកការឆ្លើយតបស្តីពីការបញ្ជាក់អះអាងអំពីវិសាលភាពក្នុងផ្នែកស្តីពី "សារណា" (សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ៣-៤) ប៉ុន្តែទឡ្ហីករណ៍ដែលបានលើកក្នុងនោះស្តីពីលក្ខខណ្ឌតម្រូវនៃដីកាលើកលែងការចោទប្រកាន់ដ៏ជាក់លាក់ ពុំត្រូវបានឆ្លើយតបក្នុងខ្លឹមសារនៃសេចក្តីសម្រេចនេះឡើយ។

[105] វិធានផ្ទៃក្នុង ៩៨(២)។

91. សហមេធាវីនាំមុខសូមបញ្ជាក់ថាបទចោទក្នុងដីកាដំណោះស្រាយ ដែលរួមបញ្ចូលឧក្រិដ្ឋកម្មសំខាន់ៗ និងទម្រង់នៃការទទួលខុសត្រូវ ដើរតួនាទីជាសំណើមួយរបស់សហចៅក្រមស៊ើបអង្កេតទៅអង្គជំនុំជម្រះសាលាដំបូង។ ដរាបណាជនជាប់ចោទត្រូវបានចោទប្រកាន់ និងត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវអំពីបទចោទទាំងនេះ ឧក្រិដ្ឋកម្មសំខាន់ៗនានា និងទម្រង់នៃការទទួលខុសត្រូវពាក់ព័ន្ធអាចត្រូវបានកំណត់ឡើងវិញតាមរយៈឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង[106]។

**(គ) សន្និដ្ឋាន**

92. ជាសន្និដ្ឋាន សហមេធាវីនាំមុខចោទប្រកាន់អំពីកំហុសជាក់ស្តែងក្នុងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងដែលប៉ះពាល់ប្រយោជន៍ភាគី និងកំហុសអង្គច្បាប់ក្នុងការអនុវត្តមិនត្រឹមត្រូវនូវច្បាប់ក្នុងការចេញសេចក្តីសម្រេចដែលរងការជំទាស់។ សហមេធាវីនាំមុខលើកឡើងថាកំហុសនីមួយៗនៃកំហុសដែលត្រូវបានចោទទាំងនេះ ធ្វើឲ្យសេចក្តីសម្រេចនេះអស់សុពលភាព។

93. សហមេធាវីនាំមុខក៏កត់សម្គាល់ឃើញថាសេចក្តីសម្រេចដែលរងការជំទាស់នេះ ត្រូវបានចេញរយៈពេលជាងប្រាំខែ បន្ទាប់ពីសំណើសុំការបញ្ជាក់បំភ្លឺត្រូវបានធ្វើ។ សំណើសុំការ បញ្ជាក់បំភ្លឺពាក់ព័ន្ធជាពិសេសនឹងមន្ទីរសន្តិសុខ ស២១ ដែលសហមេធាវីនាំមុខបានចំណាយសំណួរ ភាគច្រើនដែលផ្តោតទៅលើការរំលោភផ្លូវភេទ និងកំហុសសីលធម៌នៅមន្ទីរសន្តិសុខ ស២១[107]។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថាខ្លួនបានដកខ្លួនពីការចោទប្រកាន់លើអង្គហេតុអំពីការរំលោភផ្លូវភេទ ការចេញសេចក្តីសម្រេចដែលរងការជំទាស់ដែលត្រូវបានអូសបន្លាយ ពេលនៅជិតពេលបិទបញ្ចប់នៃសវនាការលើវគ្គនេះ បានបន្ថែមព្យសនកម្មទៅដើមបណ្តឹងរដ្ឋប្បវេណី។

94. សម្រាប់សំអាងហេតុទាំងអស់ដូចដែលបានលើកឡើងខាងលើ សហមេធាវីនាំមុខសូមស្នើសុំឲ្យធ្វើមោឃភាពសេចក្តីសម្រេចដែលរងការជំទាស់នេះ។ សហមេធាវីនាំមុខក៏ទទួចសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់បំភ្លឺអំពី *saisine* របស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការចោទប្រកាន់លើអង្គហេតុអំពីការរំលោភផ្លូវភេទក្នុងសំណុំរឿង ០០២/០២។

---

[106] វិធានផ្ទៃក្នុង ៩៨។

[107] *សូមមើល* ឧបសម្ព័ន្ធ ខ។

## VII. សំណើ

អាស្រ័យហេតុនេះ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមស្នើដោយក្ដីគោរពសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល៖

(១) ទទួលយកបណ្ដឹងឧទ្ធរណ៍បន្ទាន់នេះ

(២) ធ្វើមោឃភាពសេចក្ដីសម្រេចដែលរងការជំទាស់

(៣) សម្រេចថាអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ក្នុងការចេញសេចក្ដីសម្រេចដែលរងការជំទាស់

(៤) បញ្ជាក់អះអាងថាអង្គជំនុំជម្រះសាលាដំបូងត្រូវបានប្ដឹងឲ្យពិនិត្យនិងចាត់ការចំពោះការចោទប្រកាន់លើអង្គហេតុអំពីការរំលោភផ្លូវភេទនៅសហករណ៍ត្រាំកក់ , ស២១, និងមន្ទីរសន្តិសុខក្រាំងតាចាន់ ក្នុងសំណុំរឿង០០២/០២ និង

សូមលោក លោកស្រីចៅក្រមទទួលយកបណ្ដឹងឧទ្ធរណ៍នេះដោយក្ដីគោរពអំពីយើងខ្ញុំ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |